# ការការពារនិក្ខេបបទបញ្ចប់ថ្នាក់បណ្ឌិត

## កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

## The Reform of Community Preschool Management for Enhancing Early Childhood Education Quality in Cambodia

**ថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំ**

**ឯកទេស៖ ភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំ**

**បេក្ខជនបណ្ឌិត ៖ គីម សេដ្ឋានី**

**១០ មេសា ២០២៥**

# មាតិកា


- ជំពូកទី១ ៖ សេចក្តីផ្តើម
- ជំពូកទី២ ៖ ការរម្លឹកទ្រឹស្តី
- ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ
- ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា
- ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍






# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១ ៖ សេចក្ដីផ្ដើម

## ១.១. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការគាំពារ និងអភិវឌ្ឍកុមារតូចនៅក្នុងឆ្នាំដំបូងៗមានឥទ្ធិពលជាវិជ្ជមានសម្រាប់ជីវិតរបស់ពួកគេនៅពេលដែលពួកគេធំឡើង (UNICEF, 2018; WHO, 2018)

ការវិនិយោគលើធនធានមនុស្សសម្រាប់កុមារស្ថិតក្នុងវ័យចូលរៀននៅមត្តេយ្យសិក្សា គឺផ្តល់នូវផលត្រឡប់មកវិញខ្ពស់បំផុត (World Bank, 2010 ; Heckman, 2008)

ការវិនិយោគប្រកបដោយប្រសិទ្ធភាពក្នុងការគាំពារ និងអភិវឌ្ឍកុមារតូច កាត់បន្ថយវិសមភាពដែលកើតចេញពីភាពក្រីក្រ កង្វះអាហារូបត្ថម្ភ និងឱកាសរៀនសូត្រនានា (Hurley et al.2016; UNICEF, 2018)

ការពង្រីក និងលើកកម្ពស់គុណភាពសេវាមត្តេយ្យសិក្សាសហគមន៍នៅកម្ពុជា គឺជាជម្រើសដែលប្រសើរបំផុតក្នុងការធានាបានការអប់រំប្រកបដោយបរិយាបន្ន សមធម៌ គុណភាព ឆ្លើយតបកម្មវិធីកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យអប់រំ

ធានាថាកុមារគ្រប់រូបនឹងទទួលបាននូវការអភិវឌ្ឍក្នុងភាពជាកុមារតូចទាំងការគាំពារ និងការអប់រំនៅមត្តេយ្យសិក្សាប្រកបដោយគុណភាព សម្រាប់ត្រៀមខ្លួនគ្រប់គ្រាន់ចូលរៀននៅកម្រិតបឋមសិក្សា (អ.យ.ក.,២០២៤)

ឆ្លើយតបនឹងគោលដៅនៃការអប់រំ២០៣០ និងតម្រូវការមូលធនមនុស្សសម្រាប់ចក្ខុវិស័យអភិវឌ្ឍកម្ពុជាឆ្ពោះទៅឆ្នាំ ២០៣០ និង២០៥០ (អ. យ. ក.,២០១៩)

# ជំពូកទី១ ៖ សេចក្តីផ្តើម

## ១.២.ចំណោទបញ្ហានៃការស្រាវជ្រាវ






ក្នុងដំណើរការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងសេវាអប់រំកុមារតូច នៅឆ្នាំ ២០០៣ ក្រោមកិច្ចសហការរវាងក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី និងក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីអង្គការដៃគូអភិវឌ្ឍន៍នានា មត្តេយ្យសិក្សាសហគមន៍ត្រូវបានបង្កើតឡើងនៅតាមតំបន់គោលដៅភូមិសាស្ត្រដែលនៅឆ្ងាយ ឬពុំទាន់មានសាលាមត្តេយ្យសិក្សាសាធារណៈគ្រប់ដណ្តប់ ដើម្បីផ្តល់ឱកាសឱ្យកុមារតូចដែលមានអាយុចាប់ពី ៣ឆ្នាំ ដល់ក្រោម ៦ឆ្នាំ ទទួលបានសេវាអប់រំប្រកប ដោយសមធម៌ និងបរិយាបន្ន។

ពីឆ្នាំ២០០៣ ដល់ ឆ្នាំ២០១៣ មត្តេយ្យសិក្សាសហគមន៍មានការកើនឡើងជាលំដាប់រហូតដល់ជិត ៣ ៥០០ កន្លែង។ ប៉ុន្តែចាប់ពីឆ្នាំ២០១៣ មកមត្តេយ្យសិក្សាសហគមន៍ជាច្រើនត្រូវបានបិទទ្វារ ដោយសារគម្រោងថវិកាដែលគាំទ្រដំណើរការមត្តេយ្យសិក្សាសហគមន៍របស់ដៃគូអភិវឌ្ឍន៍ជាច្រើនត្រូវបានបញ្ចប់។

# ជំពូកទី១ ៖ សេចក្ដីផ្ដើម

## ១.២.ចំណោទបញ្ហានៃការស្រាវជ្រាវ(ត)

ឆ្នាំ២០១៧ រាជរដ្ឋាភិបាល បានចេញអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ស្ដីពី ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ សំដៅប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ ប្រមាណ ៣ ០០០ កន្លែង ដែលបានបង្កើត និងគាំទ្រដោយដៃគូអភិវឌ្ឍន៍ និងសហគមន៍ បន្តនិរន្តរភាពនៃការផ្ដល់សេវា ដោយបានកំណត់នូវធនធាននានា សម្រាប់គាំទ្រដល់កិច្ចដំណើរការ និងការអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍ ព្រមទាំងកំណត់នូវស្តង់ដាអប្បបរមារបស់មត្តេយ្យសិក្សាសហគមន៍ ។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៤៥ អនក្រ.បក
អនុក្រឹត្យ
ស្ដីពី
ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍
រាជរដ្ឋាភិបាល
- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

មត្តេយ្យសិក្សាសហគមន៍ស្តង់ដាអប្បបរមាបានកើនឡើងពី ៦០០ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ ដល់ ១ ៤៣៨ ក្នុងឆ្នាំសិក្សា២០២៣-២០២៤ ស្មើ ៤២,៩ ភាគរយ ធៀបទៅនឹងមត្តេយ្យសិក្សាសហគមន៍ទាំងអស់នៅទូទាំងប្រទេស។

ចាប់ពីឆ្នាំសិក្សា២០១៨-២០១៩ មកក្រសួងបានផ្ដល់ថវិកាគាំទ្រជាបន្តបន្ទាប់ដល់មត្តេយ្យសិក្សាសហគមន៍ដែលជាប់ស្តង់ដាអប្បបរមា សម្រាប់ឧបត្ថម្ភគ្រូ កិច្ចដំណើរការ ដែលគិតជាថវិកាសរុបជិត ១៧ លានដុល្លារអាមេរិក នៅក្នុងរយៈពេល ៧ឆ្នាំកន្លងមកនេះ(ក្នុងឆ្នាំសិក្សា២០២៣ -២០២៤ ប្រមាណ ៤,៥ លានដុល្លារអាមេរិក) ។

# លំនាំបញ្ហានៃការស្រាវជ្រាវ

បញ្ហាប្រឈមនៃវិស័យអប់រំនៅកម្ពុជា ៖ PISA-D(២០២២) លទ្ធផលសិក្សារបស់សិស្សលើគ្រប់មុខវិជ្ជាទាប សិស្សភាគច្រើនជ្រើសរើសពីសាលារៀននៅជនបទ ដែលខ្វះមូលដ្ឋានគ្រឹះនៃការសិក្សា។ កត្តានេះបង្ហាញពីទំនាក់ទំនងរបស់កុមារកម្ពុជាភាគច្រើនពុំបានឆ្លងកាត់សេវាគាំពារ និងអភិវឌ្ឍកុមារតូច ដែលមានគុណភាពឆ្លើយតបនឹងការអភិវឌ្ឍគ្រប់ជ្រុងជ្រោយរបស់កុមារតូច មិនបានត្រៀមខ្លួនឲ្យបានគ្រប់គ្រាន់ដើម្បីចូលរៀននៅបឋមសិក្សា និងកង្វះគ្រឹះសម្រាប់ការអប់រំប្រកបដោយគុណភាព។

បញ្ហាប្រឈមនៃសេវាអប់រំកុមារតូច៖ ឆ្នាំសិក្សា២០២៤-២០២៥ កុមារអាយុ ៣ឆ្នាំ ១៦,០៧% កុមារអាយុ ៤ឆ្នាំ ៤៣,១% និងកុមារអាយុ ៥ឆ្នាំ៧១,៤% ប៉ុណ្ណោះ បានទទួលសេវាអប់រំកុមារតូចគ្រប់រូបភាព។ កុមារនៅជនបទ និងតំបន់ដាច់ស្រយាលជាពិសេសកុមារក្រីក្រ និងកុមារជួបការលំបាកមានលទ្ធភាពចូលរៀនតិចតួចប៉ុណ្ណោះ។ ដូចនេះមត្តេយ្យសិក្សាសហគមន៍នឹងជួយដោះស្រាយបញ្ហាខាងលើ ដោយសារបច្ចុប្បន្នសេវាមត្តេយ្យសិក្សាសាធារណៈមិនទាន់គ្របដណ្តប់នៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលនៅឡើយ។

បញ្ហាប្រឈមនៃសេវាមត្តេយ្យសិក្សាសហគមន៍៖ ឆ្នាំសិក្សា២០២៤-២០២៥ សេវាមត្តេយ្យសិក្សាសហគមន៍បានគ្របដណ្តប់២០% នៃសេវាអប់រំកុមារតូចគ្រប់រូបភាពប៉ុន្តែបទពិសោធកុមារដែលសិក្សានៅមត្តេយ្យសិក្សាសហគមន៍មួយចំនួនដែលមិនជាប់ស្តង់ដាមានការអភិវឌ្ឍតិចតួច។ គ្រូមត្តេយ្យសិក្សាសហគមន៍ទទួលបានការបណ្តុះបណ្តាលត្រឹម ៣៥ថ្ងៃ ហើយការលើកទឹកចិត្តគ្រូនៅមានកម្រិត។ កង្វះភាពជាអ្នកដឹកនាំរបស់នាយក និងកង្វះធនធានរបស់ឃុំ សង្កាត់ ក្នុងការគាំទ្រដំណើរការមត្តេយ្យសិក្សាសហគមន៍ឱ្យមានប្រសិទ្ធភាព។ យុទ្ធសាស្ត្រ និងនីតិវិធីណែនាំអនុវត្តក្នុងការគាំទ្រដំណើរការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍នៅមានកម្រិតបើប្រៀបធៀបជាមួយមត្តេយ្យសិក្សាសាធារណៈ។

**យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍**
**ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា**

# ជំពូកទី១ ៖ សេចក្ដីផ្ដើម

## ១.៣. គោលបំណងនៃការស្រាវជ្រាវ




1. សិក្សាស្វែងយល់ពីក្របខ័ណ្ឌទស្សនាទាន នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។
2. សិក្សាពីស្ថានភាពបច្ចុប្បន្ន និងស្ថានភាពចង់ប្រែក្លាយនាពេលអនាគត នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។
3. សិក្សាស្វែងយល់ពីតម្រូវការអាទិភាព នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។
4. អភិវឌ្ឍយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។

# ជំពូកទី១ ៖ សេចក្តីផ្តើម

## ១.៤. សំណួរស្រាវជ្រាវ

1. តើក្របខ័ណ្ឌទស្សនាទាននៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីឈានដល់ការលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា មានលក្ខណៈដូចម្តេចខ្លះ ?

2. តើស្ថានភាពបច្ចុប្បន្ន និងស្ថានភាពចង់ប្រែក្លាយនាពេលអនាគតនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីឈានដល់ការលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជាមានលក្ខណៈបែបណា ?

3. តើតម្រូវការអាទិភាពនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជាមានអ្វីខ្លះ ?

4. តើយុទ្ធសាស្រ្តកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ មានលក្ខណៈបែបណាដែលអាចគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ឈានដល់ការលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ?

# ជំពូកទី១ ៖ សេចក្តីផ្តើម

## ១.៥.វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

### វិសាលភាពនៃមាតិកា ៖

- ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងអភិវឌ្ឍយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ស្របតាមស្មារតីអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ដែលបានអនុម័តនៅចុងឆ្នាំ២០១៧។
- វិធីសាស្ត្រស្រាវជ្រាវបែបបន្សំ (Combination Methods) នឹងត្រូវយកមកប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះ ដើម្បីប្រមូល និងវិភាគទិន្នន័យទាំងបរិមាណវិស័យ និងគុណវិស័យពីសំណាកគោលដៅ។
- ការសិក្សានេះចាប់ផ្តើមពីការស្រាវជ្រាវគុណវិស័យ បន្តជាមួយការស្រាវជ្រាវបរិមាណវិស័យ និងបញ្ចប់ដោយការស្រាវជ្រាវគុណវិស័យ តាម ៦ ដំណាក់កាលជាបន្តបន្ទាប់ ឆ្លើយតបវិធីសាស្ត្រស្រាវជ្រាវ និងអភិវឌ្ឍ R&D (R1D1, R2D2 និង R3D3) ។

### វិសាលភាពនៃសំណាក ៖

- ដើម្បីទទួលបានទិន្នន័យបរិមាណវិស័យ កម្រងសំណួរនឹងត្រូវចែកចាយទៅអ្នកឆ្លើយសំណួរចំនួន ៥១៩ នាក់ នៅទូទាំងប្រទេសពីសំណាកដែលបានជ្រើសរើសពីសមាសភាពថ្នាក់ដឹកនាំក្រសួង អ្នកជំនាញអប់រំកុមារតូច ថ្នាក់ដឹកនាំនាយកដ្ឋាន ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យ អ.យ.ក. នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ គ្រូមត្តេយ្យសិក្សាសហគមន៍ មាតាបិតា និងដៃគូអភិវឌ្ឍន៍។

# ជំពូកទី១ ៖ សេចក្តីផ្តើម

## ១.៦.សារប្រយោជន៍នៃការស្រាវជ្រាវ

### សារសំខាន់កម្រិតនយោបាយ

ចូលរួមវិភាគទានដល់ការផ្តល់នូវដំណោះស្រាយសមស្របសម្រាប់កំណែទម្រង់ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ក្នុងគោលបំណងធានាបាននូវការផ្តល់សេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ បរិយាបន្ន សម្រេចតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (ចំណុចដៅ ៤.២) និងការកសាងមូលធនមនុស្សសម្រាប់ចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និង២០៥០។

### សារសំខាន់កម្រិតសិក្សា

ជាប្រភពទិន្នន័យសំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវ ក្នុងការបំពេញបន្ថែមនូវខ្លឹមសារនៅក្នុងឯកសារដែលមានស្រាប់ ផ្តោតលើយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ និងការលើកកម្ពស់គុណភាពអប់រំកុមារតូច ក្នុងបរិបទកំណែទម្រង់វិស័យអប់រំកម្ពុជា។

### សារសំខាន់កម្រិតប្រតិបត្តិ

ការស្រាវជ្រាវនេះនឹងត្រូវបានប្រើជាគំរូ ដើម្បីពង្រឹងយន្តការអនុវត្តតួនាទី ភារកិច្ច និងអភិវឌ្ឍសមត្ថភាពរបស់អ្នកផ្តល់សេវា និងមន្ត្រីអប់រំកុមារតូចគ្រប់លំដាប់ថ្នាក់ ក្នុងការពង្រឹងការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ **លើកកម្ពស់ភាពជាដៃគូរដ្ឋ និងសហគមន៍ក្នុងវិស័យអប់រំ** ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដំណើរការមត្តេយ្យសិក្សាសហគមន៍។ លទ្ធផលនៃការស្រាវជ្រាវត្រូវបានគេរំពឹងថានឹងបង្កើនការទទួលសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន។

# ជំពូកទី១ ៖ សេចក្ដីផ្ដើម

## ១.៧.ក្របខ័ណ្ឌទស្សនាទាន

បន្ទាប់ពីបានសិក្សាបញ្ញត្តិទ្រឹស្ដីនានា ពិសេសបរិបទនៃកំណែទម្រង់ការគ្រប់គ្រងសាលារៀននៅកម្ពុជាចាប់តាំងពីឆ្នាំ២០១៧ *(ប្រព័ន្ធ 3As បិទជិតនៃការគ្រប់គ្រងសាលារៀន និងគោលការណ៍ 6As នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន)* អ្នកសិក្សារៀបចំសេចក្ដីព្រាងក្របខ័ណ្ឌទស្សនាទាននៃ យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ក្នុងគោលដៅពង្រឹងការគ្រប់គ្រងសាលារៀន និងកែលម្អលទ្ធផលសិក្សារបស់កុមារតូច ដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌទស្សនាទានចម្រុះថ្មីមួយដែលមាន ៤ សមាសភាគគោល គឺ ៖ (១) ស្វ័យភាព (២) ការវាយតម្លៃការសិក្សា (៣) គណនេយ្យភាព និង(៤) ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន ។

## ក្របខ័ណ្ឌទស្សនាទាននៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍

ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ (Bruns et al., 2011; Elmore, 2004; Fullan, 2007; P. Glewwe, 2014; Patrinos, Velez & Wang, 2013; Hoy& Miskel, 2008; MoEYS, 2017; UNESCO, 1989; WB, 2018)៖

១.ស្វ័យភាព៖
- ក.គណៈកម្មការគ្រប់គ្រងសាលារៀន
- ខ.ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងតាមសាលារៀន
- គ.ភាពជាអ្នកដឹកនាំរបស់នាយក

២.វង្វាយតម្លៃសិក្សា៖
- ក.កម្មវិធីអប់រំកុមារតូច និងសៀវភៅគ្រូ
- ខ.វិធីសាស្ត្ររៀន និងបង្រៀន
- គ.ការផ្សព្វផ្សាយលទ្ធផលសិក្សា

៣.គណនេយ្យភាព៖
- ក.ការបង្កើតផែនការកែលម្អសាលារៀន
- ខ.គណនេយ្យភាពរបស់នាយក
- គ.ការកែលម្អបរិស្ថានសិក្សា

៤.ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន៖
- ក.ការជ្រើសរើសបេក្ខជនមានលក្ខណៈសម្បត្តិល្អ
- ខ.ប្រាក់បៀវត្ស និងការលើកទឹកចិត្ត
- គ.ការបណ្ដុះបណ្ដាលគ្រូ

# ជំពូកទី១ ៖ សេចក្តីផ្តើម

## ១.៧.ក្របខ័ណ្ឌទស្សនាទាន

ផ្អែកលើ *និយមន័យនៃគុណភាពអប់រំកុមារតូច Whitebread, et al., (2015) ដែលបានពិនិត្យឡើងវិញជាអន្តរជាតិ គោលការណ៍ណែនាំសម្រាប់អ្នករៀបចំគោលនយោបាយអប់រំកុមារតូច ព្រមទាំង ស្តង់ដាសិក្សារបស់កុមារ ELDS ( Early Learning Development standard )* អាយុ ៣ឆ្នាំ ៤ឆ្នាំ និង ៥ឆ្នាំ ដែលជាឧបករណ៍សម្រាប់វាស់វែង និងកំណត់នូវគុណភាពនៃការអប់រំកុមារកម្រិតមត្តេយ្យសិក្សានៅក្នុងតំបន់ អ្នកសិក្សាបានរៀបចំក្របខ័ណ្ឌទស្សនាទាន នៃគុណភាពអប់រំកុមារតូចសម្រាប់ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ នូវសមាសភាគទាំង ៣ របស់កុមារគឺ ៖

( ១ ) ការអភិវឌ្ឍរាងកាយ និងចលករ

( ២ ) ការអភិវឌ្ឍពុទ្ធិបញ្ញា និង

( ៣ ) ការអភិវឌ្ឍបំណិនមិនមែនពុទ្ធិបញ្ញា។

## ក្របខ័ណ្ឌទស្សនាទាននៃគុណភាពអប់រំកុមារតូចនៅកម្ពុជា

គុណភាពនៃការអប់រំកុមារតូច (Hanushek & Woessman, 2008 Heckman, 2000; PIAGET, 1963; VYGOTSKY, 1987a; UNICEF, 2020; Whitebreat et al., 2015; Woolfolk, 2016 )៖

១. ការអភិវឌ្ឍរាងកាយ និងចលករ៖

- ១.១ អាហារូបត្ថម្ភ និងការគាំពារក្នុងរយៈពេល ១០០០ថ្ងៃដំបូងនៃកំណើត
- ១.២ បំណិនចលករកម្លាំង
- ១.៣ បំណិនចលករប៉ិនប្រសប់

២. ការអភិវឌ្ឍពុទ្ធិបញ្ញា៖

- ២.១ ការអភិវឌ្ឍភាសា និងបុរេអក្ខរកម្ម
- ២.២ បុរេគណិត
- ២.៣ បំណិនដោះស្រាយបញ្ហា

៣. ការអភិវឌ្ឍបំណិនមិនមែនពុទ្ធិបញ្ញា៖

- ៣.១ បំណិនសង្គម
- ៣.២ ស្វ័យគ្រប់គ្រង
- ៣.៤ បំណិនប្រាស្រ័យទាក់ទង

# ជំពូកទី១ ៖ សេចក្តីផ្តើម

## ១.៧.ក្របខ័ណ្ឌទស្សនទាន

ទំនាក់ទំនងនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីជួយដល់ការលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា គឺជាគោលបំណងចម្បងបំផុតនៃការសិក្សានេះ។

**(Anson, 1994; Bruns et al., 2011; Elmore, 2004; Fullan, 2007; Glewwe, 2014; Patrinos, Velez & Wang, 2013; Hoy& Miskel, 2008; MoEYS, 2017; UNESCO, 1989; WB) និង (2018; Hanushek & Woessman, 2008 Heckman, 2000; PIAGET, 1963,1970a; VYGOTSKY, 1987a; UNICEF, 2020; Whitebreat et al., 2015; Woolfolk, 2016)។**

### កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍

1. ស្វ័យភាព៖
   1. គណៈកម្មការគ្រប់គ្រងសាលារៀន
   2. ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងតាមសាលារៀន
   3. ភាពជាអ្នកដឹកនាំរបស់នាយក
2. វាយតម្លៃការសិក្សា៖
   1. កម្មវិធីអប់រំកុមារតូច និងសៀវភៅគ្រូ
   2. វិធីសាស្ត្ររៀន និងបង្រៀន
   3. ការផ្សព្វផ្សាយលទ្ធផលការសិក្សា
3. គណនេយ្យភាព៖
   1. ការបង្កើតផែនការកែលម្អសាលារៀន
   2. គណនេយ្យភាពរបស់នាយក
   3. ការកែលម្អបរិស្ថានសិក្សា
4. ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន៖
   1. ជ្រើសរើសបេក្ខជនមានលក្ខណសម្បត្តិល្អ
   2. ប្រាក់បៀវត្ស និងការលើកទឹកចិត្ត
   3. ការបណ្តុះបណ្តាលគ្រូ

### គុណភាពនៃការអប់រំកុមារតូច

1. ការអភិវឌ្ឍរាងកាយ និងចលករ
   1. អាហារូបត្ថម្ភ និងការគាំពារក្នុងរយៈពេល ១០០០ ថ្ងៃដំបូង
   2. បំណិនចលករកម្លាំង
   3. បំណិនចលករប៉ិនប្រសប់
2. ការអភិវឌ្ឍពុទ្ធិបញ្ញា៖
   1. ការអភិវឌ្ឍភាសា និងបុរេអក្ខរកម្ម
   2. បុរេគណិតវិទ្យា
   3. បំណិនដោះស្រាយបញ្ហា
3. ការអភិវឌ្ឍបំណិនមិនមែនពុទ្ធិបញ្ញា៖
   1. បំណិនសង្គម
   2. ស្វ័យគ្រប់គ្រង
   3. បំណិនប្រាស្រ័យទាក់ទង

### ការអភិវឌ្ឍយុទ្ធសាស្ត្រ៖

1. វិភាគពីស្ថានភាពបច្ចុប្បន្ន និងការចង់ប្រែក្លាយនាពេលអនាគតនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា
2. វិភាគបរិស្ថានផ្ទៃក្នុង និងផ្ទៃក្រៅ នៃមត្តេយ្យសិក្សាសហគមន៍ ដោយប្រើសន្ទស្សន៍ PNI Modified និងការវិភាគSWOT
3. អភិវឌ្ឍយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដោយប្រើការវិភាគម៉ាទ្រិច TOWS
4. កែលម្អយុទ្ធសាស្ត្រ និងបញ្ជាក់ភាពត្រឹមត្រូវនៃយុទ្ធសាស្ត្រពីអ្នកជំនាញ និងអ្នកពាក់ព័ន្ធ

**យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា**

# ជំពូកទី១ ៖ សេចក្តីផ្តើម
## ១.៨. និយមន័យពាក្យគន្លឹះ

ពាក្យគន្លឹះនៅក្នុងការសិក្សានេះ ត្រូវបានកំណត់យ៉ាងជាក់លាក់ដូចខាងក្រោម ៖

- **កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍** ៖ សំដៅទៅលើដំណើរការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដោយបញ្ចូលគ្នានូវក្របខ័ណ្ឌ 4As ដែលរួមមាន ៖ (១) ស្វ័យភាព (Autonomy), (២) ការវាយតម្លៃ (Assessment), (៣) គណនេយ្យភាព (Accountability) និង (៤) ការយកចិត្តទុកដាក់ចំពោះគ្រូបង្រៀន (Attention to Teachers) ។
- **គុណភាពអប់រំកុមារតូច** ៖ សំដៅទៅលើទំនាក់ទំនងទៅវិញទៅមករវាង (១) ការអភិវឌ្ឍរាងកាយ និងចលករ (Physical and Motor Development), (២) បំណិនពុទ្ធិបញ្ញា (Cognitive Skills) និង (៣) បំណិនមិនមែនពុទ្ធិបញ្ញា (Non-cognitive skills) ។







# ជំពូកទី២

# ការរម្លឹកទ្រឹស្តី



# ជំពូកទី២ ៖ ការរម្លឹកទ្រឹស្តី

បញ្ញត្តិ និងទ្រឹស្តីនៃកំណែទម្រង់វិស័យអប់រំជាសកល

បញ្ញត្តិ និងទ្រឹស្តីនៃកំណែ
ទម្រង់ការគ្រប់គ្រងសាលារៀន

បរិបទនៃកំណែទម្រង់វិស័យអប់រំ
និងសាលារៀននៅកម្ពុជា

កំណែទម្រង់ការគ្រប់គ្រងសាលា
មត្តេយ្យសិក្សាសាធារណៈ

កំណែទម្រង់ការគ្រប់គ្រងសាលា
មត្តេយ្យសិក្សាសហគមន៍

ក្របខ័ណ្ឌទស្សនាទាន នៃយុទ្ធសាស្ត្រកំណែ
ទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍

បញ្ញត្តិ និងទ្រឹស្តីនៃគុណភាពអប់រំកុមារតូច និង
សមាសភាគនៃគុណភាពអប់រំកុមារតូចជាសកល

ក្របខ័ណ្ឌទស្សនាទាននៃគុណភាព
អប់រំកុមារតូចនៅកម្ពុជា

បញ្ញត្តិនៃយុទ្ធសាស្ត្រគ្រប់គ្រងអប់រំ និង
ក្របខ័ណ្ឌនៃការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងអប់រំ

ការស្រាវជ្រាវពាក់ព័ន្ធ



# ជំពូកទី២ ៖ ការរម្លឹកទ្រឹស្តី

## ២.១.បញ្ញត្តិ និងទ្រឹស្តីនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍

បន្ទាប់ពីបានសិក្សាបញ្ញត្តិទ្រឹស្តីនានា បរិបទនៃកំណែទម្រង់ការគ្រប់គ្រងសាលារៀននៅកម្ពុជា អ្នកសិក្សាស្រាវជ្រាវរៀបចំសេចក្តីព្រាងក្របខ័ណ្ឌទស្សនាទាននៃយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដែលនាំមកនូវការកែលម្អគុណភាពនៃសេវាគាំពារ និងអប់រំកុមារតូចនៅកម្ពុជា ដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌទស្សនាទានចម្រុះថ្មីមួយដែលមាន ៤សមាសភាគ «4As»គឺ ៖ (១)ស្វ័យភាព (២)ការវាយតម្លៃ (៣)គណនេយ្យភាព និង(៤) ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន ។

(Anson, 1994; Bruns et al., 2011; Elmore, 2004; Fullan, 2007; Glewwe, 2014; Patrinos, Velez & Wang, 2013; Hoy& Miskel, 2008; MoEYS, 2017; UNESCO, 1989; WB, 2018)

| កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ | Anson, 1994 | Bruns et al., 2011 | Elmore, 2004 | Fullan, 2007 | Glewwe, 2014 | Hoy& Miskel, 2008 | MoEYS, 2017 | UNESCO, 1989 | WB, 2018 |
|---|---|---|---|---|---|---|---|---|---|
| **1. ស្វ័យភាព** | | | | | | | | | |
| 1.1. គណៈកម្មការគ្រប់គ្រងសាលារៀន | | | ✓ | ✓ | | ✓ | ✓ | ✓ | ✓ |
| 1.2. ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន | | ✓ | | ✓ | | ✓ | ✓ | ✓ | |
| 1.3. ភាពជាអ្នកដឹកនាំរបស់នាយក | ✓ | ✓ | | ✓ | ✓ | | ✓ | ✓ | |
| **2. វាយតម្លៃការសិក្សា** | | | | | | | | | |
| 2.1. កម្មវិធីសិក្សា និងសៀវភៅគ្រូ | | | ✓ | ✓ | | | ✓ | | ✓ |
| 2.2. វិធីសាស្ត្ររៀន និងបង្រៀន | ✓ | | ✓ | ✓ | | | ✓ | ✓ | ✓ |
| 2.3. ការផ្សព្វផ្សាយលទ្ធផលសិក្សា | | | | ✓ | | ✓ | ✓ | | ✓ |
| **3. គណនេយ្យភាព** | | | | | | | | | |
| 3.1. ការបង្កើតផែនការកែលម្អសាលារៀន | | | | | | | ✓ | ✓ | ✓ |
| 3.2. គណនេយ្យភាពរបស់នាយក | | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| 3.3. ការកែលម្អបរិស្ថានសិក្សា | | | | | | | ✓ | | ✓ |
| **4. យកចិត្តទុកដាក់ដល់គ្រូ** | | | | | | | | | |
| 4.1. ជ្រើសរើសបេក្ខជនមានលក្ខណសម្បត្តិល្អ | | ✓ | ✓ | | ✓ | | ✓ | ✓ | ✓ |
| 4.2. ប្រាក់បៀវត្ស និងការលើកទឹកចិត្ត | | ✓ | ✓ | ✓ | ✓ | | ✓ | | ✓ |
| 4.3. ការបណ្តុះបណ្តាលគ្រូ | ✓ | ✓ | | ✓ | ✓ | | ✓ | | ✓ |

# ជំពូកទី២ ៖ ការរម្លឹកទ្រឹស្តី

## ២.២.បញ្ញត្តិ និងទ្រឹស្តីនៃគុណភាពអប់រំកុមារតូច

នៅក្នុងដំណើរការនៃការធ្វើកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ សំដៅធានាឱ្យកុមារតូចគ្រប់រូបអាចទទួលបានការអប់រំប្រកបដោយគុណភាព មានការអភិវឌ្ឍគ្រប់ជ្រុងជ្រោយនូវសមាសភាគគោលទាំង ៣ របស់កុមារមេតូច ៖

(១) ការអភិវឌ្ឍរាងកាយ និងចលករ

(២) ការអភិវឌ្ឍពុទ្ធិបញ្ញា និង

(៣) ការអភិវឌ្ឍបំណិនមិនមែនពុទ្ធិបញ្ញា

(Hanushek & Woessman, 2008 Heckman, 2000; PIAGET, 1963,1970a; VYGOTSKY, 1987a; UNICEF, 2020; Whitebreat et al., 2015; Woolfolk, 2016)។

| ក្របខ័ណ្ឌគំនិតគុណភាពនៃការអប់រំកុមារតូច | Hanushek & Woessman, 2008 | Heckman, 2000 | PIAGET, 1963, 1970a | VYGOTSKY, 1987a | UNICEF, 2020 | Whitebread, et al., 2015 | Woolfolk, 2016 |
|---|---|---|---|---|---|---|---|
| **1. ការអភិវឌ្ឍរាងកាយ និងចលករ** | | | | | | | |
| (1) អាហារូបត្ថម្ភ និងការគាំពារ១០០០ថ្ងៃដំបូង | ✓ | ✓ | | | ✓ | | ✓ |
| (2) បំណិនចលករកម្លាំង | | ✓ | ✓ | | ✓ | | ✓ |
| (3) បំណិនចលករប៉ិនប្រសប់ | | ✓ | ✓ | | ✓ | | ✓ |
| **2. ការអភិវឌ្ឍពុទ្ធិបញ្ញា** | | | | | | | |
| (1) ការអភិវឌ្ឍភាសា និងបុរេអក្ខរកម្ម | | ✓ | ✓ | ✓ | | | ✓ |
| (2) បុរេគណិតវិទ្យា | | | ✓ | ✓ | | | ✓ |
| (3) បំណិនដោះស្រាយបញ្ហា | ✓ | | ✓ | ✓ | | ✓ | ✓ |
| **3. ការអភិវឌ្ឍបំណិនមិនមែនពុទ្ធិបញ្ញា** | | | | | | | |
| (1) បំណិនសង្គម | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| (2) ស្វ័យគ្រប់គ្រង | ✓ | ✓ | ✓ | | ✓ | ✓ | ✓ |
| (3) បំណិនប្រាស្រ័យទាក់ទង | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

# ជំពូកទី២ ៖ ការរម្លឹកទ្រឹស្តី

## ២.៣.បញ្ញត្តិ នៃយុទ្ធសាស្ត្រគ្រប់គ្រងអប់រំ

បន្ទាប់ពីបានសិក្សាស្រាវជ្រាវបញ្ញត្តិ និងទ្រឹស្តីដែលពាក់ព័ន្ធនានា( Drucker, 2008; Mintzberg, 1989; Hunger and Wheelen, 2011; Kaplan & Norton, 2004; Fidler, 2002; Siribanpitak, 2009; Kaufman, 2000; Wongwanich, 2005 )អ្នកសិក្សាស្រាវជ្រាវបានធ្វើការសំយោគ និងបង្កើតក្របខ័ណ្ឌទស្សនាទានមួយ ដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា តាមដំណាក់កាលដូចខាងក្រោម៖

1. សិក្សាស្វែងយល់ពីស្ថានភាពបច្ចុប្បន្ន និងការចង់បាននាពេលអនាគតនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ( Need Assessment )
2. វិភាគលើតម្រូវការអាទិភាពនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ( PNI Modified )
3. វិភាគស្ថានភាពដោយផ្អែកលើបរិយាកាសខាងក្រៅ និងបរិស្ថានផ្ទៃក្នុង( វិភាគ SWOT )
4. កំណត់បេសកកម្មរបស់អង្គភាពដើម្បីសម្រេចគោលដៅដែលចង់បានជាមូលដ្ឋាននូវការដាក់ចេញនូវជម្រើសយុទ្ធសាស្ត្រ( វិភាគ TOWS ម៉ាទ្រិច )
5. អភិវឌ្ឍសេចក្តីព្រាងយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍
6. ពិភាក្សាក្រុម និងប្រមូលគំនិតដើម្បីកែលម្អសេចក្តីព្រាងយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

# ជំពូកទី២ ៖ ការរំលឹកទ្រឹស្តី

## ២.៣.បញ្ញត្តិ នៃយុទ្ធសាស្ត្រគ្រប់គ្រងអប់រំ (ត)

| ក្របខ័ណ្ឌទស្សនាទាននៃការអភិវឌ្ឍយុទ្ធសាស្ត្រ | Kaplan and Norton (2008) | Hunger and Wheelen (2011) | Mintzberg (1989) | Drucker (2008) | Fidler (2002) | Siribanpitak (2009) | Kaufman (2000) | Suwimon Wongwanich (2005) |
|---|---|---|---|---|---|---|---|---|
| សិក្សាពីស្ថានភាពបច្ចុប្បន្ន | ✓ | | | ✓ | ✓ | | ✓ | ✓ |
| សិក្សាពីការចង់បាននាពេលអនាគត | | | ✓ | ✓ | ✓ | | ✓ | ✓ |
| កំណត់តម្រូវការអាទិភាព (PNI) | | | | | | | ✓ | ✓ |
| វិភាគស្ថានភាព៖ បរិយាកាសខាងក្រៅ បរិស្ថានផ្ទៃក្នុង (ការវិភាគ SWOT) | ✓ | ✓ | ✓ | | ✓ | ✓ | ✓ | ✓ |
| កំណត់បេសកកម្មរបស់អង្គភាពដើម្បីសម្រេចគោលដៅ និងជម្រើសយុទ្ធសាស្ត្រ (TOWS ម៉ាទ្រិច) | ✓ | ✓ | ✓ | | ✓ | ✓ | | |
| ប្រមូលគំនិត (Individual Content Validation) | ✓ | | | | | | | ✓ |
| ពិភាក្សាក្រុម ( Focus Group Discussion) | ✓ | | | | | | | ✓ |



# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ ប្រើប្រាស់វិធីសាស្ត្រទាំងបរិមាណវិស័យ និងគុណវិស័យ ដើម្បីប្រមូលទិន្នន័យពីភាគសំណាក និងអ្នកចូលរួមផ្តល់សម្ភាសន៍៖

- វិធីសាស្ត្រស្រាវជ្រាវតាមបរិមាណវិស័យ ប្រើសម្រាប់សិក្សាអំពីស្ថានភាពបច្ចុប្បន្ន និងស្ថានភាពចង់ប្រែក្លាយនាពេលអនាគតនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដោយការវិភាគយោងលើតម្រូវការចាំបាច់នៃតម្លៃសន្ទស្សន៍ (PNI Modified) របស់សូចនាករចង្អុលបង្ហាញ។
- វិធីសាស្ត្រស្រាវជ្រាវតាមបែបគុណវិស័យ ត្រូវបានប្រើដើម្បីទទួលបានទិន្នន័យពីអ្នកចូលរួមសម្ភាសន៍ ក្នុងការផ្ទៀងផ្ទាត់លើភាពត្រឹមត្រូវ (Reliability) ភាពសមស្រប (Suitability) និងលទ្ធភាពអនុវត្ត (Feasibility) នៃក្របខ័ណ្ឌទស្សនាទាន និងផ្តល់នូវធាតុចូលសម្រាប់ការវិភាគ ព្រមទាំងការសំយោគលើការអភិវឌ្ឍយុទ្ធសាស្ត្រ កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។

# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ ជាការស្រាវជ្រាវ និងអភិវឌ្ឍ (Research and Development) ដែលបែងចែកចេញជា ៦ ដំណាក់កាលជាបន្តបន្ទាប់ (R1D1, R2D2 និងR3D3 ) សំដៅអភិវឌ្ឍយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍នៅកម្ពុជាដែលរួមបញ្ចូលនូវសមាសភាពថ្មីនៃរបកគំហើញ ( Siribanpitak & Kijtorntham, 2014) ៖

- ដំណាក់កាលទី១ ៖ រម្លឹកទ្រឹស្តី សិក្សាពីក្របខ័ណ្ឌទស្សនាទាន សិក្សាអំពីស្ថានភាពបច្ចុប្បន្ន និងស្ថានភាពចង់ប្រែក្លាយនាពេលអនាគត នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ និងការវិភាគតម្រូវការអាទិភាព (R1)
- ដំណាក់កាលទី២ ៖ អភិវឌ្ឍសេចក្តីព្រាងយុទ្ធសាស្ត្រលើកទី១ (D1)
- ដំណាក់កាលទី៣ ៖ បញ្ជាក់ភាពត្រឹមត្រូវនៃសេចក្តីព្រាងយុទ្ធសាស្ត្រលើកទី១ (R2)
- ដំណាក់កាលទី៤ ៖ កែលម្អយុទ្ធសាស្ត្រ និងអភិវឌ្ឍសេចក្តីព្រាងយុទ្ធសាស្ត្រលើកទី២ (D2)
- ដំណាក់កាលទី៥ ៖ ពិភាក្សាក្រុមបញ្ជាក់ភាពត្រឹមត្រូវនៃសេចក្តីព្រាងយុទ្ធសាស្ត្រលើកទី២ (R3)
- ដំណាក់កាលទី៦ ៖ អភិវឌ្ឍយុទ្ធសាស្ត្រថ្មី (D3)

# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ
## ដ្យាក្រាមកិច្ចដំណើរការនៃការស្រាវជ្រាវ

( Research Procedure Diagram )

| គ្រប់ខ័ណ្ឌទស្សនទាននៃការអភិវឌ្ឍយុទ្ធសាស្ត្រ |
|---|
| សិក្សាពីស្ថានភាពបច្ចុប្បន្ន |
| សិក្សាពីស្ថានភាពចង់ប្រែក្លាយនាពេលអនាគត |
| កំណត់តម្រូវការអាទិភាព (PNI) |
| វិភាគស្ថានភាព៖ បរិយាកាសខាងក្រៅ បរិស្ថានផ្ទៃក្នុង (ការវិភាគ SWOT) |
| កំណត់បេសកកម្មរបស់អង្គភាពដើម្បីសម្រេចគោលដៅ និងជម្រើសយុទ្ធសាស្ត្រ (TOWS ម៉ាទ្រិច ) |
| ការពិនិត្យភាពត្រឹមត្រូវតាមខ្លឹមសារជាបុគ្គល (Individual Content Validation) |
| ពិភាក្សាក្រុម ( Focus Group Discussion) |




រូបភាពដ្យាក្រាមកិច្ចដំណើរការនៃការស្រាវជ្រាវ (Research Procedure Diagram)

# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.២. លម្អសំណាក និងការជ្រើសរើសសំណាក

ការជ្រើសរើសសំណាកសម្រាប់ការស្រាវជ្រាវបរិមាណវិស័យដោយវិធីសាស្ត្រជ្រើសរើសតាមបែបបែងចែកកម្រិត និងក្រុម *( Stratified Random Sampling )* ដោយមានការបែងចែកកម្រិតតាមខេត្ត ស្រុក ខណ្ឌ និងសាលារៀន ជាលទ្ធផលទំហំសំណាកដែលទទួលបានសរុបមានចំនួន *៥១៩ នាក់* ដោយក្នុងនោះ ៖

- ក្រុមសំណាកពីលេខរៀង១ ដល់ ៥( តារាង )ជ្រើសរើសដោយមានគោលដៅជាក់លាក់ *( purposive sampling )*។
- ក្រុមសំណាកលេខរៀង៦( តារាង )ជ្រើសរើសដោយប្រើវិធីសាស្ត្រប្រូបាបីលីតេសមាមាត្រទៅ នឹងទំហំសំណាក *(Probability Proportional to Size : PPS)*

### លម្អសំណាក និងសំណាក

| ល.រ | ក្រុមគោលដៅ | លម្អសំណាក | សំណាក |
|---|---|---|---|
| ១ | ថ្នាក់ដឹកនាំមន្ទីរ អប់រំ យុវជន និងកីឡា | ២៥ | ១៦ |
| ២ | មន្ត្រីទទួលបន្ទុកការងារអប់រំកុមារតូចថ្នាក់ខេត្ត | ២៥ | ២៥ |
| ៣ | មន្ត្រីការិយាល័យ អប់រំ យុវជន និងកីឡា | ២០៣ | ២៥ |
| ៤ | តំណាងក្រុមប្រឹក្សា ឃុំ សង្កាត់ ជាប្រធានគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ | ១ ០៣៥ | ៥០ |
| ៥ | អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់ | ១ ០៣៥ | ៥០ |
| ៦ | គ្រូបង្រៀននៅសាលា មត្តេយ្យសិក្សាសហគមន៍ | ៣ ៥៦៦ | ៣៥៣ |
| | សរុប | | ៥១៩ |

# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.២. លម្ហសំណាក និងការជ្រើសសំណាក

ផ្អែកតាមតារាង *TARO Yamane (1967)* កម្រិតលម្អៀង *៥%* លម្ហសំណាកចន្លោះពី *៣ ០០០ ទៅ ៤ ០០០* មានសំណាក ចំនួន *៣៥៣*។ គ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ចំនួន ៣៥៣នាក់ ត្រូវជ្រើសរើសជាសំណាកនៃគ្រូបង្រៀននៅមត្តេយ្យសិក្សាសហគមន៍ សរុបចំនួន ៣ ០៦៤ កន្លែងនៅទូទាំងប្រទេសសម្រាប់ទិន្នន័យ ឆ្នាំសិក្សា២០២៣-២០២៤។

ការកំណត់ទំហំសំណាករងនៅតាមរាជធានី ខេត្ត ទាំង២៥ ពីក្នុងចំណោមចំនួនសំណាកគ្រូមត្តេយ្យសិក្សាសហគមន៍ ទូទាំងប្រទេសទាំង ៣៥៣ នាក់ ត្រូវគណនាតាមវិធីសាស្ត្រប្រូបាបីលីតេសមាមាត្រទៅ នឹងទំហំសំណាក *(Probability Proportional to Size : PPS)* ។

ក្នុងចំណោមមត្តេយ្យសិក្សាសហគមន៍ ដែលនឹងជ្រើសរើស មានមត្តេយ្យដែលជាប់ស្តង់ដាខ្ពស់ និងមិនជាប់ស្តង់ដា ដែលមានដំណើរការរៀន និងបង្រៀនល្អ និងមានដំណើរការអាក់អួលដែលត្រូវបានជ្រើសរើសដោយវិធីសាស្ត្រដែលមានគោលដៅជាក់លាក់ *(Purposive sampling)*។

| ល.រ | រាជធានី-ខេត្ត | លំហសំណាក | | សំណាក | |
|---|---|---|---|---|---|
| | | ចំនួនគ្រូ | ភាគរយ | ចំនួនគ្រូ | ភាគរយ |
| 1 | បន្ទាយមានជ័យ | 58 | 1.89 % | 7 | 1.89 % |
| 2 | បាត់ដំបង | 241 | 7.87 % | 28 | 7.87 % |
| 3 | កំពង់ចាម | 166 | 5.42 % | 19 | 5.42 % |
| 4 | កំពង់ឆ្នាំង | 203 | 6.63 % | 23 | 6.63 % |
| 5 | កំពង់ស្ពឺ | 292 | 9.53 % | 34 | 9.53 % |
| 6 | កំពង់ធំ | 194 | 6.33 % | 22 | 6.33 % |
| 7 | កំពត | 128 | 4.18 % | 15 | 4.18 % |
| 8 | កណ្តាល | 148 | 4.84 % | 17 | 4.84 % |
| 9 | កែប | 12 | 0.39 % | 1 | 0.39 % |
| 10 | កោះកុង | 11 | 0.36 % | 1 | 0.36 % |
| 11 | ក្រចេះ | 119 | 3.88 % | 14 | 3.88 % |
| 12 | មណ្ឌលគិរី | 32 | 1.04 % | 4 | 1.04 % |
| 13 | ឧត្តរមានជ័យ | 95 | 3.10 % | 11 | 3.10 % |
| 14 | ប៉ៃលិន | 11 | 0.36 % | 1 | 0.36 % |
| 15 | ភ្នំពេញ | 18 | 0.59 % | 2 | 0.59 % |
| 16 | ព្រះវិហារ | 53 | 1.73 % | 6 | 1.73 % |
| 17 | ព្រៃវែង | 260 | 8.49 % | 30 | 8.49 % |
| 18 | ពោធិ៍សាត់ | 66 | 2.15 % | 8 | 2.15 % |
| 19 | រតនគិរី | 104 | 3.39 % | 12 | 3.39 % |
| 20 | សៀមរាប | 178 | 5.81 % | 21 | 5.81 % |
| 21 | ព្រះសីហនុ | 45 | 1.47 % | 5 | 1.47 % |
| 22 | ស្ទឹងត្រែង | 115 | 3.75 % | 13 | 3.75 % |
| 23 | ស្វាយរៀង | 310 | 10.12 % | 36 | 10.12 % |
| 24 | តាកែវ | 113 | 3.69 % | 13 | 3.69 % |
| 25 | ត្បូងឃ្មុំ | 92 | 3.00 % | 11 | 3.00 % |
| សរុបរួម | | **3 064** | **100 %** | **353** | **100 %** |

# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

ការរៀបចំកម្រងសំណួរផ្អែកទៅលើក្របខ័ណ្ឌទស្សនាទាន នៃការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជាដែលវាស់ដោយ ៤ សមាសភាគ ១២ សមាសភាគរង និង១២០ សូចនាករ សម្រាប់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ និងមាន ៣ សមាសភាគ ៩ សមាសភាគរង និង៧២ សូចនាករ សម្រាប់គុណភាពអប់រំកុមារតូចនៅកម្ពុជា។

សូចនាករទាំងអស់វាស់ដោយរង្វាស់លីគឃើត ៥ លំដាប់ ( 5-point Likert scale ) ដោយមានបែងចែកជាស្ថានភាពបច្ចុប្បន្ន និងស្ថានភាពរំពឹងទុកនៃសូចនាករនីមួយៗ។



# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

## ការពិនិត្យគុណភាពឧបករណ៍ប្រមូលទិន្នន័យ

កម្រងសំណួរទាំងមូលត្រូវបានឆ្លងកាត់ការពិនិត្យនូវភាពត្រឹមត្រូវតាមខ្លឹមសារ *(content validity)* ដោយមានអ្នកជំនាញចេញពីនាយកដ្ឋានអប់រំកុមារតូច អ្នកជំនាញមកពីធនាគារពិភពលោក និងអ្នកជំនាញដែលពាក់ព័ន្ធសរុបចំនួន ៧នាក់ ដែលជាលទ្ធផលសង្កេតឃើញថាពិន្ទុនៃ IOC ស្ថិតនៅក្នុងចន្លោះដែលអាចទទួលយកបានគឺនៅចន្លោះ ០.៧៧-១.០០ (Turner., & Carlson., 2003) ឬមានន័យថាកម្រងសំណួរនេះមានភាពត្រឹមត្រូវតាមខ្លឹមសារដែលអាចយកទៅប្រើប្រាស់ដើម្បីប្រមូលទិន្នន័យសាកល្បងបាន។



# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

## ការពិនិត្យគុណភាពឧបករណ៍ប្រមូលទិន្នន័យ

**កិច្ចពិភាក្សាក្រុមលើកម្រងសំណួរ**

(ថ្ងៃទី១៣ ដល់ ១៤ មិថុនា ឆ្នាំ២០២៤)

បន្ថែមពីនេះអ្នកស្រាវជ្រាវក៏បាន យកកម្រងសំណួរទៅឆ្លងកាត់កិច្ចពិភាក្សាក្រុម (២០នាក់)ពីអ្នកជំនាញអប់រំកុមារតូចបន្ថែមទៀតដើម្បីឱ្យកាន់តែមានភាពជឿជាក់។











# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

## ការពិនិត្យគុណភាពឧបករណ៍ប្រមូលទិន្នន័យ

### ការសាកល្បងប្រមូលទិន្នន័យជាមួយក្រុម សំណាកដែលមានលក្ខណៈស្រដៀង

(ថ្ងៃទី០៥ កក្កដា ឆ្នាំ២០២៤)

កម្រងសំណួរត្រូវបានសាកល្បងប្រមូលទិន្នន័យជាមួយក្រុមសំណាកដែលមានលក្ខណៈស្រដៀងគ្នាជាមួយក្រុមសំណាកគោលដៅពិតចំនួន ៥០នាក់ ដើម្បីពិនិត្យមើលភាពត្រឹមត្រូវតាមបរិបទ (face validity) និងពិនិត្យភាពជឿជាក់។

ភាពជឿជាក់ (internal consistency reliability) នៃឧបករណ៍ស្រាវជ្រាវគ្រប់សមាសភាគទាំងអស់ស្ថិតនៅក្នុងលក្ខខណ្ឌល្អប្រសើរអាចប្រើប្រាស់សម្រាប់យកទៅប្រមូលទិន្ន័យពិតជាមួយក្រុមសំណាកគោលដៅបានដែលតម្លៃរបស់វាស្ថិតនៅចន្លោះ ពី ០.៨៩ ដល់ ០.៩៥ (Hair, et al., 2019; Kline, 2009) ។









# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ
## ការពិនិត្យគុណភាពឧបករណ៍ប្រមូលទិន្នន័យ

ភាពជឿជាក់ *(internal consistency reliability)* នៃឧបករណ៍ស្រាវជ្រាវគ្រប់សមាសភាគទាំងអស់ស្ថិតនៅក្នុងលក្ខខណ្ឌល្អប្រសើរ អាចប្រើប្រាស់សម្រាប់យកទៅប្រមូលទិន្នន័យពិតជាមួយក្រុមសំណាកគោលដៅបាន ដែលតម្លៃរបស់វាស្ថិតនៅចន្លោះពី ០.៨៩ ដល់ ០.៩៥ (Hair, et al., 2019; Kline, 2009) ។

| សមាភាគរង (sub-component) | ចំនួនសូចនាករ | តម្លៃភាពជឿជាក់ |
|---|---|---|
| **ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍** | | |
| គណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ | 10 | 0.90 |
| ការចូលរួមសហគមន៍ក្នុងការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ | 10 | 0.91 |
| ភាពជាអ្នកដឹកនាំរបស់នាយក/នាយិកាសាលាមត្តេយ្យសិក្សាសហគមន៍ | 10 | 0.94 |
| កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សាសហគមន៍ | 10 | 0.92 |
| វិធីសាស្ត្របង្រៀន និងរៀន | 10 | 0.91 |
| ការផ្សព្វផ្សាយលទ្ធផលសិក្សា | 10 | 0.91 |
| ការបង្កើតផែនការកែលម្អសាលាមត្តេយ្យសិក្សាសហគមន៍ | 10 | 0.94 |
| គណនេយ្យភាពរបស់នាយក | 10 | 0.95 |
| ការកែលម្អបរិស្ថានសិក្សា | 10 | 0.93 |
| ការជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិល្អ | 10 | 0.92 |
| ប្រាក់ឧបត្ថម្ភនិងការលើកទឹកចិត្ត | 10 | 0.89 |
| ការបណ្តុះបណ្តាលគ្រូបង្រៀន | 10 | 0.89 |
| **គុណភាពអប់រំកុមារតូច** | | |
| អាហារូបត្ថម្ភនិងការគាំពារក្នុងរយៈពេល១០០០ថ្ងៃដំបូង | 8 | 0.89 |
| បំណិនចលករកម្លាំង | 8 | 0.92 |
| បំណិនចលករប៉ិនប្រសប់ | 8 | 0.93 |
| ការអភិវឌ្ឍភាសា និងបុរេអក្ខរកម្ម | 8 | 0.91 |
| បុរេគណិត | 8 | 0.92 |
| បំណិនដោះស្រាយបញ្ហា | 8 | 0.93 |
| បំណិនសង្គម | 8 | 0.91 |
| ស្វ័យគ្រប់គ្រង | 8 | 0.92 |
| បំណិនប្រាស្រ័យទាក់ទង | 8 | 0.92 |

# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

## ការពិនិត្យគុណភាពឧបករណ៍ប្រមូលទិន្នន័យ

ការពិនិត្យគុណភាពកម្រងសំណួរចុងក្រោយមុនពេលចុះប្រមូលទិន្នន័យជាក់ស្តែង គឺការស្នើសុំពិនិត្យក្រមសីលធម៌លើការប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យស្រាវជ្រាវ ទៅក្រុមប្រឹក្សាវិទ្យាសាស្ត្រ នៃវិទ្យាស្ថានជាតិអប់រំ។

បន្ទាប់ពីទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃវិទ្យាស្ថានជាតិអប់រំ និងក្រសួងអប់រំ យុវជន និងកីឡាអ្នកស្រាវជ្រាវ បានចាប់ផ្តើមរៀបកម្មវិធីចុះប្រមូលទិន្នន័យជាក់ស្តែងឆ្លើយនូវសំណួរស្រាវជ្រាវនានាដែលមានកំណត់នៅក្នុងជំពូកទី១។



# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.៤. ការប្រមូលទិន្នន័យ

- ក្រុមការងារប្រមូលទិន្នន័យ ចំនួន ២០ រូប ត្រូវបានទទួលការតម្រង់ទិស ពីនីតិវិធី នៃការប្រមូលទិន្នន័យ និងខ្លឹមសារនៃកម្រងសំណួរមុនដំណើរការប្រមូលទិន្នន័យផ្ទាល់ដល់គោលដៅទាំង ២៥ រាជធានី ខេត្ត។



**ការតម្រង់ទិសពីនីតិវិធី នៃការប្រមូលទិន្នន័យ**
(ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៤)







# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.៤. ការប្រមូលទិន្នន័យ

**សកម្មភាពនៃការចុះប្រមូលទិន្នន័យ**
**(ថ្ងៃទី០៥ ដល់ ១៦ ខែសីហា ឆ្នាំ២០២៤)**

- កម្រងសំណួរត្រូវបានយកទៅដល់ដៃរបស់សំណាកគោលដៅទាំងអស់គ្នា ក្នុងពេលវេលាជាក់លាក់ ដើម្បីឲ្យអ្នកឆ្លើយតបកម្រងសំណួរបានបំពេញ កម្រងសំណួរប្រកបដោយការជឿជាក់។













# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.៥. ការវិភាគទិន្នន័យ

- ក្នុងការវិភាគពីស្ថានភាពបច្ចុប្បន្ន និង ស្ថានភាពចង់ប្រែក្លាយនាពេលអនាគតនៃ កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យ សិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណ ភាពអប់រំកុមារតូចនៅកម្ពុជា អ្នកសិក្សា ប្រើប្រាស់កម្មវិធីវិភាគស្ថិតិ *SPSS* ដើម្បី កំណត់ពិន្ទុមធ្យមភាគ និងគម្លាតស្តង់ដា *ដើម្បីរកឱ្យឃើញកម្រិតនៃភាពខុសគ្នា* ។




| | Name | Type | Width | Decimals | Label | Values | Missing | Columns | Align | Measure | Role |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | Group | Numeric | 8 | 2 | | {1.00, stand... | None | 8 | Right | Nominal | Input |
| 2 | position | Numeric | 8 | 2 | | {1.00, teach... | None | 8 | Right | Nominal | Input |
| 3 | sex | Numeric | 8 | 2 | | {1.00, male}... | None | 8 | Right | Nominal | Input |
| 4 | age | Numeric | 8 | 2 | | {1.00, lower ... | None | 8 | Right | Nominal | Input |
| 5 | edulevel | Numeric | 8 | 2 | | {1.00, lower ... | None | 8 | Right | Nominal | Input |
| 6 | experience | Numeric | 8 | 2 | current work ex... | None | None | 8 | Right | Nominal | Input |
| 7 | PrinC1 | Numeric | 8 | 2 | | None | None | 8 | Right | Nominal | Input |
| 8 | PrinC2 | Numeric | 8 | 2 | | None | None | 8 | Right | Nominal | Input |
| 9 | PrinC3 | Numeric | 8 | 2 | | None | None | 8 | Right | Nominal | Input |
| 10 | PrinC4 | Numeric | 8 | 2 | | None | None | 8 | Right | Nominal | Input |
| 11 | PrinC5 | Numeric | 8 | 2 | | None | None | 8 | Right | Nominal | Input |
| 12 | PrinC6 | Numeric | 8 | 2 | | None | None | 8 | Right | Nominal | Input |
| 13 | PrinC7 | Numeric | 8 | 2 | | None | None | 8 | Right | Nominal | Input |
| 14 | PrinC8 | Numeric | 8 | 2 | | None | None | 8 | Right | Nominal | Input |
| 15 | PrinC9 | Numeric | 8 | 2 | | None | None | 8 | Right | Nominal | Input |
| 16 | PrinC10 | Numeric | 8 | 2 | | None | None | 8 | Right | Nominal | Input |




```
COMPUTE NutrianC=(NutrianC1 + NutrianC2 + NutrianC3 + NutrianC4 + NutrianC5 + NutrianC6 + NutrianC7
  + NutrianC8)/8.
EXECUTE.
COMPUTE MotoForC=(MotoForC1 + MotoForC2 + MotoForC3 + MotoForC4 + MotoForC5 + MotoForC6 + MotoForC7
  + MotoForC8)/8.
EXECUTE.
COMPUTE MotoSkiC=(MotoSkiC1 + MotoSkiC2 + MotoSkiC3 + MotoSkiC4 + MotoSkiC5 + MotoSkiC6 + MotoSkiC7
  + MotoSkiC8)/8.
EXECUTE.
COMPUTE LanDevC=(LanDevC1 + LanDevC2 + LanDevC3 + LanDevC4 + LanDevC5 + LanDevC6 + LanDevC7 +
  LanDevC8)/8.
EXECUTE.
COMPUTE RethMathC=(ReMathC1 + ReMathC2 + ReMathC3 + ReMathC4 + ReMathC5 + ReMathC6 + ReMathC7 +
  ReMathC8)/8.
```

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា



# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.១. លទ្ធផលទី១ ៖ ក្របខ័ណ្ឌទស្សនាទាន នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គោរពជូន
ឯកឧត្តម កែវ សារ៉ាត់ ទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា

**កម្មវត្ថុ** ៖ ការបញ្ជាក់ភាពត្រឹមត្រូវនៃក្របខណ្ឌទស្សនាទាន (Validity of conceptual framework)។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជូនឯកឧត្តមជ្រាបថា៖និស្សិតថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំ ជំនាន់ទី១ នៃវិទ្យាស្ថានជាតិអប់រំ ឈ្មោះ **គឹម សេដ្ឋានី** បានសរសេរគម្រោងនិក្ខេបបទស្រាវជ្រាវថ្នាក់បណ្ឌិត របស់ខ្លួន ស្តីពី "**កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូច នៅកម្ពុជា**" ដែលមានរូបខ្ញុំ **បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ជាគ្រូណែនាំគោល បានឆ្លងកាត់ការការពារគម្រោងស្រាវជ្រាវពិស្តាររួចហើយ។ ដំណាក់កាលបន្ទាប់និស្សិតត្រូវធ្វើការប្រមូលទិន្នន័យជាលក្ខណៈគុណវិស័យ ដោយធ្វើការសម្ភាសន៍ដោយផ្ទាល់ ឬ តាមប្រព័ន្ធអនឡាញ ជាមួយអ្នកជំនាញចំនួន ៣ នាក់ និងអ្នកមានបទពិសោធន៍លើការងារពាក់ព័ន្ធចំនួន ៣ នាក់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវលើក្របខណ្ឌទស្សនាទាន (Validity) នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម អនុញ្ញាតផ្តល់បទសម្ភាសន៍ដោយផ្ទាល់ ឬ តាមប្រព័ន្ធអនឡាញរយៈពេលពី ៦០ ទៅ ៩០ នាទី ក្នុងការបញ្ជាក់ពីភាពត្រឹមត្រូវ នៃក្របខណ្ឌទស្សនាទានយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ក្នុងពេលវេលាសមស្របណាមួយនៅក្នុងសប្តាហ៍ទី១ ឬ ទី២ ខែកុម្ភៈ ឆ្នាំ២០២២ ដោយអនុគ្រោះ (សូមជូនភ្ជាប់នូវសេចក្តីសង្ខេបការលើកទ្រឹស្តី)។

សូម **ឯកឧត្តម** មេត្តាទទួលការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

ថ្ងៃអង្គារ ១រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២
**ហត្ថលេខា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

- Keys informants : អ្នកបញ្ជាក់ភាពត្រឹមត្រូវលើក្របខណ្ឌទស្សនាទាន

| អ្នកជំនាញ (Experts) | អ្នកមានបទពិសោធ (Implementors) |
|---|---|
| ▪ មានសញ្ញាបត្របណ្ឌិតផ្នែកគ្រប់គ្រងអប់រំ<br>▪ មានបទពិសោធក្នុងការបំពេញការងារក្នុងការងារអប់រំរយៈពេលលើសពី ៥ឆ្នាំ<br>▪ បាននឹងកំពុងបំពេញការងារក្នុងវិស័យអប់រំនៅកម្ពុជា<br>▪ ជាអ្នកសិក្សាស្រាវជ្រាវទៅលើការងារគ្រប់គ្រងអប់រំ | ▪ មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់<br>▪ មានបទពិសោធក្នុងការបំពេញការងារនៅក្រសួងអប់រំលើស១០ឆ្នាំ<br>▪ បាននឹងកំពុងបំពេញការងារក្នុងវិស័យអប់រំកុមារតូចនៅកម្ពុជា ជាអ្នកអនុវត្តផ្ទាល់លើការដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់អប់រំ |

- Interview Protocol : មគ្គុទ្ទេសន៍សម្ភាសន៍ និងទម្រង់សម្ភាសន៍
- Key Performance Indicators: ផ្ទៀងផ្ទាត់នូវសូចនាករប្រតិបត្តិសំខាន់ៗ

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

1. គូសបន្ថែមក្របខ័ណ្ឌទស្សនាទាននៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ និងក្របខ័ណ្ឌទស្សនាទានគុណភាពការអប់រំកុមារតូច ស្ថិតក្នុងប្រអប់មួយជាមួយគ្នា។
2. កែសម្រួលសមាសភាគ«ការអភិវឌ្ឍភាសា» ទៅជា «ការអភិវឌ្ឍភាសា និងបុរេអក្ខរកម្ម» ដែលមានលក្ខណៈជាបញ្ញត្តិរួមជាមួយគ្នាដោយរក្សា «បុរេគណិតវិទ្យា» នៅដាច់ដោយឡែក។
3. កែសម្រួលពាក្យពេចន៍បន្តិចបន្តួច។
4. ប្រអប់ក្រោមបន្ថែមពាក្យ «យុទ្ធសាស្ត្រ» នៅខាងមុខ ឆ្លើយតបគោលបំណងទី៤ នៃការស្រាវជ្រាវ។



# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវស្រាវ

### ៤.១.២. លទ្ធផលទី២ ៖ ស្ថានភាពបច្ចុប្បន្ន និងស្ថានភាពចង់ប្រែក្លាយនាពេលអនាគត នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

- សមាសភាគនីមួយៗ នៃស្ថានភាពបច្ចុប្បន្នសុទ្ធតែទាបជាងសមាសភាគនីមួយៗនៃស្ថានភាពចង់ប្រែក្លាយនាពេលអនាគតនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ដែលតម្លៃមធ្យមភាគសរុបរួមគឺខុសគ្នាចំនួន 1.41 នៃតម្លៃមធ្យមភាគ បង្ហាញឲ្យឃើញថា វាជាតម្លៃគម្លាតមួយដែលគួរឲ្យចាប់ អារម្មណ៍។

| កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា | ស្ថានភាពបច្ចុប្បន្ន | | | | ស្ថានភាពរំពឹងទុក | | | |
|---|---|---|---|---|---|---|---|---|
| | M | SD | កម្រិត | លំដាប់ | M' | SD' | កម្រិត' | លំដាប់' |
| ១. ស្វ័យភាព | 3.22 | 0.63 | មធ្យម | 4 | 4.70 | 0.42 | ខ្ពស់ | 1 |
| ២. វាយតម្លៃការសិក្សា | 3.42 | 0.54 | មធ្យម | 1 | 4.66 | 0.43 | ខ្ពស់ | 4 |
| ៣. គណនេយ្យភាព | 3.24 | 0.62 | មធ្យម | 2 | 4.70 | 0.40 | ខ្ពស់ | 1 |
| ៤. ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន | 3.24 | 0.55 | មធ្យម | 3 | 4.67 | 0.41 | ខ្ពស់ | 3 |
| សរុបរួម | 3.28 | 0.53 | មធ្យម | | 4.69 | 0.39 | ខ្ពស់ | |

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.២. លទ្ធផលទី២ ៖ ស្ថានភាពបច្ចុប្បន្ន និងស្ថានភាពចង់ប្រែក្លាយនាពេលអនាគត នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ( បច្ច័យខាងក្នុង )

- តាមរយៈរូបភាពបង្ហាញថា សមាសភាគនីមួយៗ នៃស្ថានភាពបច្ចុប្បន្នសុទ្ធតែទាបជាងសមាសភាគនីមួយៗ នៃស្ថានភាពចង់ប្រែក្លាយនាពេលអនាគតនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ។ *ដូច្នេះ គេអាចសន្និដ្ឋានបានថាការអនុវត្តការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍នាពេលបច្ចុប្បន្នទាមទារឲ្យមានការធ្វើកំណែទម្រង់ដោយមានយុទ្ធសាស្ត្រជាក់លាក់ ដើម្បីឈានដល់ការលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ។*



# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.២. លទ្ធផលទី២ ៖ ស្ថានភាពបច្ចុប្បន្ន និងស្ថានភាពចង់ប្រែក្លាយនាពេលអនាគត នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍( បច្ច័យខាងក្រៅ )

➢ សមាសភាគបច្ច័យខាងក្រៅនីមួយៗនៃស្ថានភាពបច្ចុប្បន្នសុទ្ធតែទាបជាងសមាសភាគនីមួយៗនៃស្ថានភាពរំពឹងទុកនៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ដែលតម្លៃមធ្យមភាគសរុបរួមគឺខុសគ្នាចំនួន 1.40 នៃតម្លៃមធ្យមភាគ បង្ហាញឲ្យឃើញថា វាជាតម្លៃគម្លាតមួយដែលគួរឲ្យចាប់អារម្មណ៍ ។

| កំណែទម្រង់ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា | | បច្ច័យខាងក្រៅ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | នយោបាយ | | សេដ្ឋកិច្ច | | សង្គម | | បច្ចេកវិទ្យា | | សរុប | |
| | | បច្ចុប្បន្ន | ចង់បាន | បច្ចុប្បន្ន | ចង់បាន | បច្ចុប្បន្ន | ចង់បាន | បច្ចុប្បន្ន | ចង់បាន | បច្ចុប្បន្ន | ចង់បាន |
| ១. ស្វ័យភាព | M | 3.22 | 4.70 | 3.29 | 4.70 | 3.38 | 4.70 | 3.02 | 4.61 | **3.23** | **4.68** |
| | S.D | 0.70 | 0.62 | 0.69 | 0.38 | 0.64 | 0.42 | 0.89 | 0.55 | **0.68** | **0.61** |
| | កម្រិត | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ |
| ២. វង្វាយតម្លៃ | M | 3.42 | 4.66 | 3.62 | 4.77 | 3.53 | 4.74 | 3.11 | 4.57 | **3.42** | **4.68** |
| | S.D | 0.63 | 0.70 | 0.56 | 0.36 | 0.58 | 0.39 | 0.69 | 0.53 | **0.68** | **0.60** |
| | កម្រិត | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ |
| ៣. គណនេយ្យភាព | M | 3.24 | 4.70 | 3.13 | 4.66 | 3.05 | 4.58 | 3.52 | 4.77 | **3.24** | **4.68** |
| | S.D | 0.69 | 0.63 | 0.63 | 0.47 | 0.86 | 0.64 | 0.64 | 0.38 | **0.68** | **0.62** |
| | កម្រិត | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ |
| ៤. ការយកចិត្តទុកដាក់ចំពោះគ្រូបង្រៀន | M | 3.24 | 4.67 | 3.66 | 4.78 | 3.00 | 4.66 | 3.07 | 4.67 | **3.24** | **4.69** |
| | S.D | 0.69 | 0.59 | 0.56 | 0.37 | 0.67 | 0.50 | 0.69 | 0.47 | **0.68** | **0.60** |
| | កម្រិត | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ |
| **សរុប** | **M** | **3.28** | **4.68** | **3.43** | **4.73** | **3.24** | **4.67** | **3.18** | **4.65** | 3.28 | 4.68 |
| | **S.D** | **0.70** | **0.61** | **0.67** | **0.61** | **0.66** | **0.60** | **0.68** | **0.60** | 0.68 | 0.61 |
| | **កម្រិត** | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ |

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.២. លទ្ធផលទី២ ៖ ស្ថានភាពបច្ចុប្បន្ន និងស្ថានភាពចង់ប្រែក្លាយនាពេលអនាគត នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍(បច្ច័យខាងក្រៅ)

- តាមរយៈរូបភាពនេះបង្ហាញឱ្យឃើញកាន់តែច្បាស់ថែមទៀតនូវស្ថានភាពបច្ចុប្បន្ន និងស្ថានភាពដែលចង់បាននៃសមាសភាគបច្ច័យខាងក្រៅទាំងបួន។ គេសង្កេតឃើញថាស្ថានភាពបច្ចុប្បន្នជារួមទាបជាងស្ថានភាពចង់បានថ្វីត្បិតតែសមាសភាគនីមួយៗមានតម្លៃមិនស្មើគ្នាក៏ដោយ ។



# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.៣. លទ្ធផលទី៣ ៖ តម្រូវការអាទិភាព នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

លទ្ធផលនៃការវិភាគទិន្នន័យគឺត្រូវប្រើប្រាស់ដើម្បីកំណត់(១)ភាពខ្លាំង (២)ភាពទន់ខ្សោយ (៣)ឱកាស និង(៤)ការគំរាមកំហែងនៃកំណែទម្រង់ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ នឹងត្រូវបែងចែកចេញជា ០២ផ្នែក ៖

ខ.១. ភាពខ្លាំង និងភាពខ្សោយ នៃកំណែទម្រង់ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ដែលធនធានផ្ទៃក្នុង។

ខ.២. ឱកាស និងការគំរាមកំហែង នៃកំណែទម្រង់ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ដែលជាបច្ច័យខាងក្រៅ។

ការគណនាតម្រូវការអាទិភាពPNI modified ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម៖

$$PNI\ modified = (I-D)/D$$

I (Importance) តំណាងឱ្យតម្លៃមធ្យមនៃស្ថានភាពចង់ប្រែក្លាយនាពេលអនាគត

D (Degree of Success) តំណាងឱ្យតម្លៃមធ្យមនៃស្ថានភាពបច្ចុប្បន្ន

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.៣. លទ្ធផលទី៣ ៖ តម្រូវការអាទិភាព នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

**ចំណុចខ្លាំង ចំណុចខ្សោយ**

តម្លៃ PNI modified ស្ថិតនៅចន្លោះពី 0.36 ដល់ 0.46 ។ ដូច្នេះគេអាចកំណត់តម្លៃផ្នែកក្នុងនៃការញែក PNI modified ជាក្រុមខ្ពស់ និងក្រុមទាបបានដូចខាងក្រោម៖

( 0.46 + 0.36 )៖ 2 = 0.41 អាស្រ័យលើតម្លៃនេះគេអាចកំណត់ក្រុម PNI modified ខ្ពស់ និងទាបដូចខាងក្រោម ៖

- PNI modified ខ្ពស់មានតម្លៃចាប់ពី 0.41 ដល់តម្លៃ 0.46 (ចំណុចខ្សោយ)
- PNI modified ទាបមានតម្លៃចាប់ពី 0.36 ដល់តម្លៃ 0.40 (ចំណុចខ្លាំង)
- *PNI modified សរុបរួមមានតម្លៃ 0.43 ចាត់ទុកថាជា ចំណុចខ្សោយ*

| តម្រូវការចាំបាច់អាទិភាពនៃការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា | PNI modified | លំដាប់ | S/W |
|---|---|---|---|
| ១. ស្វ័យភាព | 0.46 | 1 | W |
| ២. វាយតម្លៃការសិក្សា | 0.36 | 4 | S |
| ៣. គណនេយ្យភាព | 0.45 | 2 | W |
| ៤. ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន | 0.44 | 3 | W |
| **សរុបរួម** | **0.43** | | **W** |

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.៣. លទ្ធផលទី៣ ៖ តម្រូវការអាទិភាព នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

- ស្វ័យភាពមានតម្លៃ PNI modified ខ្ពស់ជាងគេគឺ 0.46 គណនេយ្យភាពមានតម្លៃ PNI modified បន្ទាប់គឺ 0.45 ហើយការយកចិត្តទុកដាក់ចំពោះគ្រូបង្រៀនមានតម្លៃ PNI modified ស្មើនឹង 0.44 ដែលបង្ហាញថាជាតម្លៃដែលស្ថិតនៅក្នុងចំណុចខ្សោយ ចំណែកការវាយតម្លៃការសិក្សាមានតម្លៃ PNI modified ស្មើនឹង 0.36 បញ្ជាក់ថាវាជាចំណុចខ្លាំងដែលសាលាមាន។

ចំណុចខ្លាំង ចំណុចខ្សោយ



# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.៣. លទ្ធផលទី៣ ៖ តម្រូវការអាទិភាព នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍

**ចំណុចខ្លាំង ចំណុចខ្សោយ**

| ១. ស្វ័យភាព | PNI modified | លំដាប់ | S/W |
|---|---|---|---|
| **១.គណៈកម្មការគ្រប់គ្រងសាលារៀន** | **0.47** | **4** | **S** |
| ១.១.ការអភិវឌ្ឍរាងកាយនិងចលករ | 0.47 | 20 | S |
| ១.១.១.អាហារូបត្ថម្ភ និងការគាំពារក្នុងរយៈពេល១០០០ថ្ងៃដំបូងនៃកំណើត | 0.48 | 3 | W |
| ១.១.២.បំណិនចលករ កម្លាំង | 0.50 | 39 | S |
| ១.១.៣.បំណិនចលករប៊ិនប្រសប់ | 0.43 | 36 | S |
| ១.២. ការអភិវឌ្ឍពុទ្ធិបញ្ញា | 0.36 | 27 | S |
| ១.២.១.ការអភិវឌ្ឍភាសា និងបុរេអក្ខរកម្ម | 0.54 | 33 | S |
| ១.២.២.បុរេគណិតវិទ្យា | 0.45 | 29 | S |
| ១.២.៣.បំណិនដំណោះស្រាយបញ្ហា | 0.39 | 16 | S |
| ១.៣.ការអភិវឌ្ឍបំណិនមិនមែនពុទ្ធិបញ្ញា | 0.6 | 27 | S |
| ១.៣.១.បំណិនសង្គម | 0.45 | 29 | S |
| ១.៣.២.ស្វ័យគ្រប់គ្រង | 0.47 | 20 | S |
| ១.៣.៣.បំណិនប្រាស្រ័យទាក់ទង | 0.5 | 29 | S |
| **២. ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលា** | **0.44** | **7** | **S** |
| ១.១.ការអភិវឌ្ឍរាងកាយនិងចលករ | 0.49 | 16 | S |
| ១.១.១.អាហារូបត្ថម្ភនិងការគាំពារក្នុងរយៈពេល១០០០ថ្ងៃដំបូងនៃកំណើត | 0.50 | 2 | W |
| ១.១.២.បំណិនចលករ កម្លាំង | 0.42 | 37 | S |
| ១.១.៣.បំណិនចលករប៊ិនប្រសប់ | 0.34 | 33 | S |
| ១.២. ការអភិវឌ្ឍពុទ្ធិបញ្ញា | 0.47 | 20 | S |
| ១.២.១.ការអភិវឌ្ឍភាសា និងបុរេអក្ខរកម្ម | 0.45 | 29 | S |
| ១.២.២.បុរេគណិតវិទ្យា | 0.36 | 27 | S |
| ១.២.៣.បំណិនដំណោះស្រាយបញ្ហា | 0.40 | 14 | S |
| ១.៣.ការអភិវឌ្ឍបំណិនមិនមែនពុទ្ធិបញ្ញា | 0.47 | 20 | S |
| ១.៣.១.បំណិនសង្គម | 0.47 | 20 | S |
| ១.៣.២.ស្វ័យគ្រប់គ្រង | 0.38 | 18 | S |
| ១.៣.៣.បំណិនប្រាស្រ័យទាក់ទង | 0.47 | 20 | S |
| **៣. ភាពជាអ្នកដឹកនាំរបស់នាយក** | **0.47** | **4** | **W** |
| ១.១.ការអភិវឌ្ឍរាងកាយនិងចលករ | 0.45 | 6 | W |
| ១.១.១.អាហារូបត្ថម្ភនិងការគាំពារក្នុងរយៈពេល១០០០ថ្ងៃដំបូងនៃកំណើត | 0.58 | 1 | W |
| ១.១.២.បំណិនចលករ កម្លាំង | 0.38 | 18 | S |
| ១.១.៣.បំណិនចលករប៊ិនប្រសប់ | 0.40 | 14 | S |

| ២. វង្វាយតម្លៃការសិក្សា | PNI modified | លំដាប់ | S/W |
|---|---|---|---|
| **១.កម្មវិធីអប់រំកុមារតូច និងសៀវភៅគ្រូ** | **0.32** | **37** | **S** |
| ១.១.ការអភិវឌ្ឍរាងកាយនិងចលករ | 0.37 | 20 | S |
| ១.១.១.អាហារូបត្ថម្ភនិងការគាំពារក្នុងរយៈពេល១០០០ថ្ងៃដំបូងនៃកំណើត | 0.48 | 3 | W |
| ១.១.២.បំណិនចលករ កម្លាំង | 0.31 | 39 | S |
| ១.១.៣.បំណិនចលករប៊ិនប្រសប់ | 0.33 | 36 | S |
| ១.២. ការអភិវឌ្ឍពុទ្ធិបញ្ញា | 0.36 | 26 | S |
| ១.២.១.ការអភិវឌ្ឍភាសា និងបុរេអក្ខរកម្ម | 0.34 | 33 | S |
| ១.២.២.បុរេគណិតវិទ្យា | 0.35 | 29 | S |
| ១.២.៣.បំណិនដំណោះស្រាយបញ្ហា | 0.39 | 16 | S |
| ១.៣.ការអភិវឌ្ឍបំណិនមិនមែនពុទ្ធិបញ្ញា | 0.36 | 26 | S |
| ១.៣.១.បំណិនសង្គម | 0.35 | 29 | S |
| ១.៣.២.ស្វ័យគ្រប់គ្រង | 0.37 | 20 | S |
| យុទ្ធសាស្ត្រទី២<br>យុទ្ធសាស្ត្ររង២.១ | គណនេយ្យភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា<br>ជំរុញការរៀបចំផែនការអភិវឌ្ឍសាលារៀនដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា |
|---|---|
| | ២.១. បង្កើនឥទ្ធិពលផ្នែកនយោបាយ សេដ្ឋកិច្ច សង្គមវប្បធម៌ និងបច្ចេកវិទ្យាក្នុងការជំរុញបង្កើតផែនការអភិវឌ្ឍសាលារៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ដោយផ្តោតលើការផ្តល់អាហារូបត្ថម្ភនិងការ គាំពារកុមារតូចជាពិសេសក្នុងអំឡុងពេល ១ ០០០ថ្ងៃដំបូងនៃកំណើត បំណិន ចលករតូច បំណិនចលករធំ ការអភិវឌ្ឍ ភាសា បុរេសំណេរ បុរេគណិតវិទ្យា បំណិនដោះស្រាយបញ្ហា បំណិនសង្គម ស្វ័យគ្រប់គ្រង និងបំណិនប្រាស្រ័យទាក់ទង |
| | *១. ក្រសួងអប់រំ យុវជន និងកីឡា ៖*<br>▪ រៀបចំសេចក្តីណែនាំនានា សម្រាប់ ជំរុញដល់ការ បង្កើតផែនការ អភិវឌ្ឍ សាលាមត្តេយ្យសិក្សាសហគមន៍<br>▪ ពង្រីកការទទួលស្គាល់គុណភាពអប់រំ តាមរយៈការប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ស្តង់ដាទៅជា ឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ<br>▪ រៀបចំយន្តការដើម្បី គាំទ្រ និង ពង្រឹងសាលាមត្តេយ្យសិក្សាសហគមន៍ និងប្រែក្លាយទៅជាសាលាមត្តេយ្យសិក្សាសាធារណៈ<br>▪ រៀបចំយន្តការគាំទ្រ និងពង្រឹងសាលាមត្តេយ្យសិក្សាសាធារណៈឱ្យក្លាយជាសាលាមត្តេយ្យសិក្សាគំរូ |
| | *២. នាយកដ្ឋានអប់រំកុមារតូច ៖*<br>▪ ផ្តល់ប្រឹក្សាបច្ចេកទេសនានា រៀបចំវគ្គបណ្តុះបណ្តាលនៅក្នុងការបង្កើតផែនការកែលម្អសាលាមត្តេយ្យសិក្សាសហគមន៍<br>▪ ចុះវាយតម្លៃគុណភាពអប់រំ និងលើកសំណើដើម្បីប្រែក្លាយសាលាមត្តេយ្យសិក្សាសហគមន៍ស្តង់ដាទៅជា ឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ<br>▪ ចុះគាំទ្រ និង ពង្រឹងសាលាមត្តេយ្យសិក្សាសហគមន៍ លើកសំណើដើម្បី ប្រែក្លាយទៅជាសាលាមត្តេយ្យសិក្សាសាធារណៈ<br>▪ ចុះគាំទ្រ និងពង្រឹងសាលាមត្តេយ្យសិក្សាសាធារណៈ លើកសំណើដើម្បី ប្រែក្លាយជាសាលាមត្តេយ្យសិក្សាគំរូ |
| | *៣. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ៖*<br>▪ សហការណ៍ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង -ស្រុកខណ្ឌ និងនាយកដ្ឋានអប់រំកុមារតូចចុះគាំទ្រ និងពង្រឹងសាលា មត្តេយ្យ |

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.៣. លទ្ធផលទី៤ ៖ យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ចុងក្រោយ ( D3 )

*២.៣.ពង្រឹងការកែលម្អបរិស្ថានសិក្សាដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា៖*

- រៀបចំ និងអនុម័តស្តង់ដាអគារសិក្សាសម្រាប់មត្តេយ្យសិក្សាសហគមន៍ ដោយមានច្រើនជម្រើស( អគារឈើ អគារថ្ម មួយបន្ទប់ ឬពីរបន្ទប់... ) រួមនិងទីធ្លាល្បែងសិក្សា ស្របតាមវិធីសាស្ត្របង្រៀនថ្មី។

| | |
|---|---|
| យុទ្ធសាស្ត្រទី២<br>យុទ្ធសាស្ត្ររង២.៣ | គណនេយ្យភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា<br>ជំរុញការកែលម្អបរិស្ថានសិក្សា សាលារៀនដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា |
| កិច្ចដំណើរការ | ២.៣.បង្កើនឥទ្ធិពលផ្នែកនយោបាយ សេដ្ឋកិច្ច សង្គមវប្បធម៌ និងបច្ចេកវិទ្យាក្នុងការពង្រឹងការកែលម្អបរិស្ថានសិក្សា ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ដោយផ្តោតលើការផ្តល់អាហារូបត្ថម្ភនិងការគាំពារកុមារតូចជាពិសេសក្នុងអំឡុងពេល ១ ០០០ថ្ងៃដំបូងនៃកំណើត បំណិនចលករតូច បំណិនចលករធំ ការអភិវឌ្ឍភាសា បុរេសំណេរ បុរេគណិតវិទ្យា បំណិនដោះស្រាយបញ្ហា បំណិនសង្គមស្វ័យគ្រប់គ្រង និងបំណិនប្រាស្រ័យទាក់ទង ។ |
| | *១. ក្រសួងអប់រំ យុវជន និងកីឡា ៖*<br>▪ បន្តវិនិយោគទៅលើការពង្រីង និងពង្រីកសាលាមត្តេយ្យសិក្សារដ្ឋតាមគោលការណ៍បង្កើតមត្តេយ្យសិក្សាយ៉ាងតិចមួយបន្ទប់ នៅក្នុងសាលាបឋមសិក្សារដ្ឋមួយ<br>▪ បន្តសម្របសម្រួលជាមួយដៃគូអភិវឌ្ឍ អាជ្ញាធរមូលដ្ឋាន ដើម្បីរៀបចំសាលាមត្តេយ្យសិក្សាសហគមន៍ឱ្យមានស្តង់ដា<br>▪ រៀបចំប្រព័ន្ធតាមដាននិងវាយតម្លៃ ( M&E )ដើម្បីបញ្ចូលសាលាមត្តេយ្យសិក្សាសហគមន៍ដែលមានស្តង់ដាឱ្យក្លាយទៅជាឧបសម្ព័ន្ធនៃបឋមសិក្សាឬមត្តេយ្យសិក្សារដ្ឋដាច់ដោយឡែក<br>▪ រៀបចំ និងអ នុម័តស្តង់ដាអគារសិក្សាសម្រាប់មត្តេយ្យសិក្សាសហគមន៍ ដោយមានច្រើនជម្រើស( អគារឈើ អគារថ្ម មួយបន្ទប់ ឬពីរបន្ទប់... ) |
| | *៣. នាយកដ្ឋានអប់រំកុមារតូច ៖*<br>▪ បណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកការអប់រំកុមារតូច នៅរាជធានី-ខេត្ត ដើម្បីពង្រឹងយន្តការM&E<br>▪ ផ្តល់ប្រឹក្សាបច្ចេកទេសនានា និងពង្រឹងការកែលម្អបរិស្ថានសិក្សាសម្រាប់ មត្តេយ្យសិក្សាសហគមន៍ |
| | *២. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ៖*<br>▪ ពង្រឹងយន្តការM&E និងគាំទ្រដល់ការកែលម្អបរិស្ថានសិក្សា និងពង្រឹងគុណភាពនៃការផ្តល់សេវាមត្តេយ្យសិក្សាសហគមន៍<br>▪ សហការណ៍ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុកខណ្ឌ និងក្រុមប្រឹក្សាឃុំ-សង្កាត់ បន្តកៀរគរធនធានតាមសហគមន៍ដើម្បីបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍តាមលទ្ធភាព |
| | *៤. ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក ៖*<br>▪ ចុះពិនិត្យ ផ្តល់ការគាំទ្រដល់ការកែលម្អបរិស្ថានសិក្សា ដើម្បីកែលម្អ លទ្ធផលសិក្សាសិស្ស ជាពិសេសបរិស្ថានហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈសិក្សា និងការរៀបចំបន្ទប់រៀន និងទីធ្លាល្បែងសិក្សា |
| | *៥. ក្រុមប្រឹក្សាឃុំ-សង្កាត់ ៖* |

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.៣. លទ្ធផលទី៤ ៖ យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ចុងក្រោយ ( D3 )

*៣.១. ពង្រឹងការជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិល្អជាគ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា៖*

- ត្រូវបង្កើនចំនួនគ្រូមត្តេយ្យសិក្សា ដើម្បីដោះស្រាយបញ្ហាខ្វះគ្រូ ដោយបណ្តុះបណ្តាល និងធ្វើការផ្តល់អាជ្ញាបណ្ណសម្រាប់បំពេញតម្រូវការគ្រូមត្តេយ្យសិក្សាគ្រប់រូបភាព
- ស្នើសុំគោលការណ៍ទៅក្រសួងមុខងារសាធារណៈ ជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យារបស់រដ្ឋ បង្រៀននៅសាលាមត្តេយ្យសិក្សាសហគមន៍ស្តង់ដាឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ
- រៀបចំយន្តការវាយតម្លៃ ទទួលស្គាល់គ្រូមត្តេយ្យសិក្សាសហគមន៍ ដែលមានបទពិសោធ។

| យុទ្ធសាស្ត្រទី៣<br>យុទ្ធសាស្ត្ររង៣.១ | យកចិត្តទុកដាក់ដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា<br>បង្កើនការយកចិត្តទុកដាក់ដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា |
|---|---|
| កិច្ចដំណើរការ | ៣.១.បង្កើនឥទ្ធិពលផ្នែកនយោបាយ សេដ្ឋកិច្ច សង្គមវប្បធម៌ និងបច្ចេកវិទ្យាក្នុងការពង្រឹងការជ្រើសរើសបេក្ខជនមានលក្ខណសម្បត្តិល្អជាគ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ដោយផ្តោតលើការផ្តល់អាហារូបត្ថម្ភនិងការគាំពារកុមារតូចជាពិសេសក្នុងអំឡុងពេល ១ ០០០ថ្ងៃដំបូងនៃកំណើត បំណិនចលករតូច បំណិនចលករធំ ការអភិវឌ្ឍភាសាបុរេសំណេរ បុរេគណិតវិទ្យា បំណិនដោះស្រាយបញ្ហា បំណិនសង្គមស្វ័យគ្រប់គ្រង និងបំណិនប្រាស្រ័យទាក់ទង ។ |
| | *១. ក្រសួងអប់រំ យុវជន និងកីឡា ៖*<br>▪ ត្រូវបង្កើនចំនួនគ្រូមត្តេយ្យសិក្សា ដើម្បីដោះស្រាយបញ្ហាខ្វះគ្រូ ដោយបណ្តុះបណ្តាលនិងធ្វើការផ្តល់អាជ្ញាបណ្ណសម្រាប់បំពេញតម្រូវការគ្រូមត្តេយ្យសិក្សាគ្រប់រូបភាព<br>▪ កំណត់លក្ខខណ្ឌ និងសេចក្តីណែនាំជាក់លាក់សម្រាប់ពង្រឹងការជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិល្អ ជាគ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ពិសេសសម្រាប់បង្រៀននៅមត្តេយ្យសិក្សាសហគមន៍ស្តង់ដា<br>▪ រៀបចំប្រព័ន្ធលើកទឹកចិត្តដើម្បីទាក់ទាញអ្នកដែលមានសម ត្ថភាពឱ្យចូលធ្វើគ្រូមត្តេយ្យសិក្សាសហគមន៍ស្តង់ដា<br>▪ ស្នើសុំគោលការណ៍ទៅក្រសួងមុខងារសាធារ ណៈ ជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យារបស់រដ្ឋ បង្រៀននៅសាលាមត្តេយ្យសិក្សា សហគមន៍ស្តង់ដាឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ<br>▪ រៀបចំយន្តការវាយតម្លៃ ទទួលស្គាល់គ្រូមត្តេយ្យសិក្សាសហគមន៍ ដែលមានបទពិសោធន៍ |
| | *២. នាយកដ្ឋានអប់រំកុមារតូច ៖*<br>▪ ផ្តល់ប្រឹក្សាបច្ចេកទេស ពង្រឹងការជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិល្អជាគ្រូបង្រៀនសម្រាប់សាលាមត្តេយ្យសិក្សាសហគមន៍<br>▪ ផ្តល់ការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពគ្រូមត្តេយ្យសិក្សាសហគមន៍ជាប្រចាំ ដើម្បីពង្រឹងការយកចិត្តទុកដាក់ដល់គ្រូបង្រៀន |
| | *៣. មន្ទីរអប់រំ យុវជន និងកីឡា ៖*<br>▪ សហការជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង-ស្រុក ខណ្ឌ ពង្រឹងការជ្រើសរើសបេក្ខជនមានលក្ខណសម្បត្តិល្អជាគ្រូបង្រៀននៅមត្តេយ្យសិក្សាសហគមន៍ |
| | *៤. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង -ស្រុក ខណ្ឌ ៖* |

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.៣. លទ្ធផលទី៤ ៖ យុទ្ធសាស្រ្តកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ចុងក្រោយ ( D3 )

*៣.២.បង្កើនប្រាក់បៀវត្ស លើកទឹកចិត្តគ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា៖*

- សហការជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំបើកផ្តល់ប្រាក់បៀវត្សប្រចាំជារៀងរាល់ខែ ដល់គ្រូបង្រៀនសាលាមត្តេយ្យសិក្សាសហគមន៍ស្តង់ដា។
- ស្នើសុំគោលការណ៍ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនដល់គ្រូមត្តេយ្យសិក្សាសហគមន៍ស្តង់ដានូវរបបបេឡាសន្តិសុខសង្គមដូចគ្រូបង្រៀនជាប់កិច្ចសន្យារបស់រដ្ឋ។

| | |
|---|---|
| យុទ្ធសាស្រ្តទី៣<br>យុទ្ធសាស្រ្តរង៣.២ | យកចិត្តទុកដាក់ដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា<br>បង្កើនប្រាក់បៀវត្ស និងលើកទឹកចិត្តគ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា |
| កិច្ចដំណើរការ | ៣.២. បង្កើនឥទ្ធិពលផ្នែកនយោបាយ សេដ្ឋកិច្ច សង្គមវប្បធម៌ និងបច្ចេកវិទ្យា ក្នុងការបង្កើនប្រាក់បៀវត្សនិងការលើកទឹកចិត្តដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ដោយផ្តោតលើការផ្តល់អាហារូបត្ថម្ភនិងការគាំពារកុមារតូចជាពិសេសក្នុងអំឡុងពេល ១ ០០០ថ្ងៃដំបូងនៃកំណើត បំណិនចលករតូច បំណិនចលករធំ ការអភិវឌ្ឍ ភាសា បុរេសំណេរ បុរេគណិតវិទ្យា បំណិនដោះស្រាយបញ្ហា បំណិនសង្គម ស្វ័យគ្រប់គ្រង និងបំណិនប្រាស្រ័យទាក់ទង ។ |
| | *១. ក្រសួងអប់រំ យុវជន និងកីឡា៖*<br>▪ ពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើសុំបង្កើនប្រាក់បៀវត្ស និងការលើកទឹកចិត្តនានាដល់គ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ស្តង់ដា<br>▪ សហការជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំបើកផ្តល់ប្រាក់បៀវត្សប្រចាំជារៀងរាល់ខែ ដល់គ្រូបង្រៀនសាលាមត្តេយ្យសិក្សាសហគមន៍ស្តង់ដា<br>▪ ស្នើសុំគោលការណ៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជូនដល់គ្រូមត្តេយ្យសិក្សាសហគមន៍ស្តង់ដានូវរបបបេឡាសន្តិសុខសង្គមដូចគ្រូបង្រៀនជាប់កិច្ចសន្យារបស់រដ្ឋ។ |
| | *២. នាយកដ្ឋានអប់រំកុមារតូច ៖*<br>▪ សម្របសម្រួលនីតិវិធីក្នុងការ បើកផ្តល់ប្រាក់បៀវត្សនិងការលើកទឹកចិត្តឱ្យបានទៀងទាត់ដល់គ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ស្តង់ដា<br>▪ ផ្តល់ការបណ្តុះបណ្តាល វគ្គបំប៉នបន្ថែមនានា ដល់គ្រូបង្រៀនសាលាមត្តេយ្យសិក្សាសហគមន៍<br>▪ បង្កលក្ខណៈឱ្យមានការប្រកួតប្រជែងលើស្នាដៃអប់រំកុមារ និងផ្តល់បណ្ណ សរសើរលើកទឹកចិត្តគ្រូដែលមានស្នាដៃល្អ |
| | *៣. ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង -ស្រុក ខណ្ឌ ៖*<br>▪ លើកទឹកចិត្តដល់គ្រូបង្រៀន ចូលរួមក្នុងការសិក្សាស្រាវជ្រាវលើការអប់រំកុមារ ឬការស្រាវជ្រាវប្រតិបត្តិ<br>▪ លើកទឹកចិត្ត និងគាំទ្រគ្រូបង្រៀនក្នុងការអនុវត្តវិធីសាស្រ្តបង្រៀនថ្មីៗ និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀនកុមារ |
| | *៤. ក្រុមប្រឹក្សាឃុំ-សង្កាត់ ៖*<br>▪ ផ្តល់ថវិកាលើកទឹកចិត្តបន្ថែមដល់គ្រូមត្តេយ្យសិក្សាសហគមន៍ជាប់ស្តង់ដា<br>▪ ផ្តល់ប្រាក់បៀវត្ស និងការលើកទឹកចិត្តនានា ដល់គ្រូមត្តេយ្យសិក្សាសហគមន៍ដែលមិនទាន់ជាប់ស្តង់ដា<br>▪ ឆ្លើយតបទាន់ពេលវេលាលើបញ្ហាប្រឈមនានារបស់គ្រូបង្រៀនមត្តេយ្យ សិក្សាសហគមន៍ |

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.៣. លទ្ធផលទី៤ ៖ យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ចុងក្រោយ ( D3 )

*៣.៣. ពង្រឹងការបណ្តុះបណ្តាលគ្រូប្រកបដោយគុណភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា៖*

- ធ្វើទំនើបកម្មសាលាមធ្យមសិក្សាគរុកោសល្យ ប្រែក្លាយទៅជាវិទ្យាស្ថានគរុកោសល្យមត្តេយ្យសិក្សា (ប្រព័ន្ធអប់រំឧត្តមសិក្សាដែលប្រើប្រាស់ក្រេឌីត ១២+៤ ) និងបង្កើនគុណវុឌ្ឍិគ្រូឧទ្ទេសឱ្យដល់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់យ៉ាងទាបបំផុត
- រៀបចំវគ្គបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ឱ្យមានស្តង់ដាយ៉ាងហោចណាស់សមមូលសញ្ញាបត្រមធ្យមសិក្សា ដោយបង្កើនរយៈពេលបណ្តុះបណ្តាល និងឱ្យមានស្តង់ដា (ចាប់ពី ៣៥ថ្ងៃឡើងទៅ)។

| | |
|---|---|
| យុទ្ធសាស្ត្រទី៣<br>យុទ្ធសាស្ត្រង៣.៣ | យកចិត្តទុកដាក់ដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា<br>ពង្រឹងការបណ្តុះបណ្តាលគ្រូប្រកបដោយគុណភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា |
| កិច្ចដំណើរការ | ៣.៣. បង្កើនឥទ្ធិពលផ្នែកនយោបាយ សេដ្ឋកិច្ច សង្គមវប្បធម៌ និងបច្ចេកវិទ្យា ក្នុងការពង្រឹងការបណ្តុះបណ្តាលគ្រូប្រកបដោយគុណភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ដោយផ្តោតលើការផ្តល់អាហា រូបត្ថម្ភនិងការគាំពារកុមារតូចជាពិសេសក្នុងអំឡុងពេល ១ ០០០ថ្ងៃដំបូងនៃកំណើត បំណិនចលករតូច បំណិនចលករធំ ការអភិវឌ្ឍភាសា បុរេសំណេរ បុរេគណិតវិទ្យា បំណិនដោះស្រាយបញ្ហា បំណិនសង្គម ស្វ័យគ្រប់គ្រង និងបំណិនប្រាស្រ័យទាក់ទង ។ |
| | *១. ក្រសួងអប់រំ យុវជន និងកីឡា ៖*<br>▪ ធ្វើទំនើបកម្មសាលាមធ្យមសិក្សាគរុកោសល្យ ប្រែក្លាយទៅជាវិទ្យាស្ថានគរុកោសល្យមត្តេយ្យសិក្សា (ប្រព័ន្ធអប់រំឧត្តមសិក្សាដែលប្រើប្រាស់ក្រេឌីត១២+៤) និងទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធផ្នែករឹងនិងទន់(បង្កើនគុណវុឌ្ឍិគ្រូឧទ្ទេសឱ្យដល់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់)<br>▪ កែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា និងពិនិត្យកែឯកសារបណ្តុះបណ្តាលនានា និងពិនិត្យកែលម្អវិធីសាស្ត្របង្រៀនមត្តេយ្យសិក្សា ដើម្បីឆ្លើយតបគោលដៅក្នុងការអប់រំអាកប្បកិរិយា បុគ្គលិកលក្ខណៈ ចរិយាធម៌ សិល្បៈ និងវប្បធម៌ត្រៀមខ្លួនសម្រាប់យុទ្ធសាស្ត្រ និងចក្ខុវិស័យជាតិ ២០៥០ |
| | *២. នាយកដ្ឋានអប់រំកុមារតូច ៖*<br>▪ រៀបចំវគ្គបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ឱ្យមានស្តង់ដាយ៉ាងហោចណាស់សមមូលសញ្ញាបត្រមធ្យមសិក្សា ដោយបង្កើនរយៈពេលបណ្តុះបណ្តាលនិងឱ្យមានស្តង់ដា (ពី៣៥ថ្ងៃឡើងទៅ)<br>▪ ផ្តល់ការបំប៉នដំបូងតាមស្តង់ដា រយៈពេល៣៥ថ្ងៃ ដល់គ្រូមត្តេយ្យសិក្សា សហគមន៍ពីការងាររដ្ឋបាលសាលារៀន បច្ចេកទេស និងការផលិតសម្ភារៈឧបទេសសម្រាប់រៀន និងបង្រៀន<br>▪ ផ្តល់ការបណ្តុះបណ្តាលជំនាញប្រឹក្សាគរុកោសល្យកុមារតូច និងជំនាញទំនាក់ទំនងអន្តរបុគ្គល ដល់គ្រូមត្តេយ្យសិក្សាសហគមន៍ |
| | *៣. មន្ទីរអប់រំ យុវជន និងកីឡា ៖*<br>▪ សហការជាមួយអាជ្ញាធររាជធានី-ខេត្ត និងក្រុមប្រឹក្សាឃុំ-សង្កាត់និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក-ខណ្ឌ រៀបចំកម្មវិធីបណ្តុះ បណ្តាលមាតាបិតា អ្នកអាណាព្យាបាលផ្សារភ្ជាប់មត្តេយ្យសិក្សាសហគមន៍ ស្តីពីសារៈសំខាន់នៃ១០០០ថ្ងៃដំបូង និងការចិញ្ចឹមបីបាច់កូនឱ្យបានត្រឹមត្រូវ<br>▪ ប្រមូល និងបូកសរុបតម្រូវការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ ជូនក្រសួងអប់រំ យុវជន និងកីឡា |

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.៣. លទ្ធផលទី៤ ៖ យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ចុងក្រោយ ( D3 )

***៤.៣.ផ្តល់ព័ត៌មានដល់មាតាបិតា អាណាព្យាបាលពីលទ្ធផលសិក្សាសិស្ស ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា៖***

- កំណត់លក្ខខណ្ឌជាក់លាក់ មគ្គទេសក៍ត្រឹមត្រូវ ឬសេចក្តីណែនាំនានាក្នុងការផ្តល់ព័ត៌មានដល់មាតាបិតា អាណាព្យាបាលពីលទ្ធផលសិក្សាសិស្សមត្តេយ្យសិក្សាសហគមន៍
- ផ្តល់ការបណ្តុះបណ្តាល ពីការវាយតម្លៃ និងការផ្តល់ព័ត៌មានដល់មាតាបិតា អាណាព្យាបាលពីលទ្ធផលសិក្សាសិស្សមត្តេយ្យសិក្សាសហគមន៍ ជៀសវាងពីការផ្សព្វផ្សាយជាសាធារណៈ ។

| | |
|---|---|
| យុទ្ធសាស្ត្រទី៤<br>យុទ្ធសាស្ត្ររង៤.៣ | រង្វាយតម្លៃសិក្សា ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា<br>ផ្តល់ព័ត៌មានដល់មាតាបិតា អ្នកអាណាព្យាបាលពីលទ្ធផលសិក្សាសិស្ស ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា |
| កិច្ចដំណើរការ | ៤.៣. លើកកម្ពស់នយោបាយ សេដ្ឋកិច្ច សង្គមវប្បធម៌ និងបច្ចេកវិទ្យាក្នុងការផ្តល់ព័ត៌មានដល់មាតាបិតា អ្នកអាណាព្យាបាលពីលទ្ធផលសិក្សាសិស្ស ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា ដោយផ្តោតលើការផ្តល់អាហារូបត្ថម្ភនិង ការគាំពារកុមារតូច ជាពិសេសក្នុងអំឡុងពេល ១ ០០០ថ្ងៃ ដំបូងនៃកំណើត បំណិន ចលករតូច បំណិនចលករធំ ការអភិវឌ្ឍភាសា បុរេសំណេរ បុរេគណិតវិទ្យា បំណិនដោះស្រាយបញ្ហា បំណិនសង្គម ស្វ័យគ្រប់គ្រង និងបំណិនប្រាស្រ័យទាក់ទង។ |
| | *១. ក្រសួងអប់រំ យុវជន និងកីឡា ៖*<br>▪ កំណត់លក្ខខណ្ឌជាក់លាក់ មគ្គទេសក៍ត្រឹមត្រូវ ឬសេចក្តីណែនាំនានាក្នុងការផ្តល់ព័ត៌មានដល់មាតាបិតា អ្នកអាណាព្យាបាលពីលទ្ធផលសិក្សាសិស្ស មត្តេយ្យសិក្សាសហគមន៍ |
| | *២. នាយកដ្ឋានអប់រំកុមារតូច ៖*<br>▪ ផ្តល់ការបណ្តុះបណ្តាល ពីការវាយតម្លៃ និងការផ្តល់ព័ត៌មានដល់មាតាបិតា អ្នកអាណាព្យាបាលពីលទ្ធផលសិក្សាសិស្សមត្តេយ្យសិក្សាសហគមន៍ ដោយជៀសវាងពីការផ្សព្វផ្សាយជាសាធារណៈ |
| | *៣. មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ៖*<br>▪ ផ្តល់ការគាំទ្របច្ចេកទេស និងពង្រឹងការអនុវត្តនីតិវិធីនៃការវាយតម្លៃ លទ្ធផលសិក្សាសិស្ស និងការផ្តល់ព័ត៌មានដល់មាតាបិតា អ្នកអាណាព្យាបាល |
| | *៤. ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក ខណ្ឌ ៖*<br>▪ ចុះត្រួតពិនិត្យ កែលម្អ ការអនុវត្តរបស់សាលារៀនក្នុងការផ្តល់ព័ត៌មានដល់មាតាបិតា អ្នកអាណាព្យាបាលពីលទ្ធផលសិក្សាសិស្សដោយផ្ទាល់ ដោយមិនធ្វើការផ្សព្វផ្សាយជាសាធារណៈ<br>▪ បូកសរុប និងផ្តល់របាយការណ៍ពីលទ្ធផលសិក្សាសិស្សជូនមន្ទីរអប់រំ យុវជន និងកីឡា |
| | *៥. សាលារៀន ៖*<br>▪ កត់ត្រាលទ្ធផលសិក្សារបស់កុមារក្នុងសៀវភៅតាមដានការសិក្សាបានទៀងទាត់<br>▪ ផ្តល់ព័ត៌មានពីលទ្ធផលសិក្សារបស់កុមារ ជូនមាតាបិតា និងអ្នកអាណាព្យាបាលទៀងទាត់ ដោយមិនធ្វើការផ្សព្វផ្សាយជាសាធារណៈ<br>▪ បង្កើតប្រព័ន្ធទំនាក់ទំនងនានាជាមួយមាតាបិតា និងអ្នកអាណាព្យាបាលកុមារជាមួយគណៈគ្រប់គ្រងសាលា<br>▪ ផ្តល់ព័ត៌មានដល់មាតាបិតា ដោយផ្អែកលើលទ្ធផលការតាមដានការលូតលាស់របស់កុមារ |

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

សមាសភាគ «4As» នៃកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សា សហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

នាយកសាលា មានតួនាទីស្នូលក្នុងការ ដឹកនាំកំណែទម្រង់ការ គ្រប់គ្រងសាលាមត្តេយ្យ សិក្សាសហគមន៍

**១.ស្វ័យភាព (Autonomy)** ភាពជាអ្នកដឹកនាំរបស់នាយកសាលាក្នុងការ ៖
- ត្រួតពិនិត្យការអនុវត្តកម្មវិធីសិក្សា
- គ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន
- សម្របសម្រួលការចូលរួមរបស់សហគមន៍

**២.គណនេយ្យភាព (Accountability)** គណនេយ្យភាពរបស់នាយកសាលាក្នុងការ ៖
- រៀបចំ និងផ្សព្វផ្សាយពីកិច្ចបញ្ជីការរបស់សាលា
- ធានាការប្រើប្រាស់ធនធានសមស្របនឹងតម្រូវការអភិវឌ្ឍសាលារៀន
- ផ្តល់ព័ត៌មានលទ្ធផលសិក្សាដល់មាតាបិតា

**៣.ការវាយតម្លៃការសិក្សា (Assessment)** នាយកសាលាដឹកនាំវាយតម្លៃ ៖
- គុណភាពអប់រំកុមារតូចឱ្យបានត្រឹមត្រូវ
- គុណភាពគ្រូបង្រៀនដោយតម្លាភាព
- ការអនុវត្តរបស់សាលារៀន

**៤.យកចិត្តទុកដាក់ដល់គ្រូបង្រៀន (Attention to teacher)**

នាយកសាលាមានតួនាទី ៖
- ជួយជ្រើសរើសបានគ្រូបង្រៀនល្អ
- ផ្តល់ឱកាសដល់គ្រូបង្រៀនបានអភិវឌ្ឍជំនាញជាប្រចាំ
- ជួយដោះស្រាយការលំបាក និងលើកទឹកចិត្តគ្រូ



# ជំពូកទី៤

# ការពិភាក្សាស្តីពី

# របកគំហើញនៃការស្រាវជ្រាវ

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្តីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.១. ស្ថានភាពបច្ចុប្បន្ន និងស្ថានភាពចង់ប្រែក្លាយនាពេលអនាគត នៃគំរូលំនាំទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

#### ក. ការវិភាគបរិស្ថានខាងក្នុង

- ចំណុចគន្លឹះនៃគំរូលំនាំទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ត្រូវផ្តោតលើការកែលម្អវប្បធម៌ធ្វើការងារ និងគុណតម្លៃ ។ *វប្បធម៌សាលារៀន (School culture)* គឺជាឥរិយាបថ អាកប្បកិរិយា និងគុណតម្លៃ ដែលប៉ះពាល់ដល់ប្រសិទ្ធភាពដំណើរការសាលារៀន ( Fullan, 2007)។ ហង់ជួន (២០២០) បានសង្កត់ធ្ងន់ផងដែរថា *វប្បធម៌សាលារៀន ឬការរៀបចំរបៀបរបបដំណើរការ គឺជាមូលដ្ឋានគ្រឹះនៃកិច្ចដំណើរការនៃសាលារៀនល្អ។*
- ដើម្បីបង្កើតឱ្យមានវប្បធម៌ការសិក្សារៀនសូត្រ និងការសម្រេចនូវឧត្តមភាព នាយកសាលាត្រូវរៀបចំបញ្ជីលទ្ធផលការសិក្សាដែលត្រូវសម្រេចបាន និងវិធានការដែលគណៈគ្រប់គ្រង និងគ្រូត្រូវអនុវត្ត ដើម្បីសម្រេចបានតាមគោលដៅដែលបានដាក់ចេញ។
- វប្បធម៌សាលារៀនត្រូវផ្តោតលើ៖ (១)**បេសកកម្ម និងតម្លៃរួម៖** ក្របខ័ណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងវិធីសាស្ត្របង្រៀន យន្តការវាយតម្លៃការសិក្សា ការអនុវត្តសកម្មភាពក្រៅម៉ោងសិក្សា ការបណ្តុះនូវបំណិនសង្គម (២)**ទំនាក់ទំនង៖** សាមគ្គីភាពផ្ទៃក្នុង (៣)**ការចូលរួមពីមាតាបិតា និងសហគមន៍៖** ផែនការអភិវឌ្ឍរយៈពេលមធ្យម ដែលមានការចូលរួម។

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្តីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.១.ស្ថានភាពបច្ចុប្បន្ន និងស្ថានភាពចង់ប្រែក្លាយនាពេលអនាគត នៃគំរូណែនាំទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

#### ខ. ការវិភាគបច្ច័យខាងក្រៅ

- គុណភាពនៃការអប់រំកុមារតូចនៅតាមសាលាមត្តេយ្យសិក្សាសហគមន៍ គេត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើកត្តាផ្សេងៗទៀតដូចជា៖(១)**កត្តានយោបាយ** ៖ស្ថិរភាពនយោបាយ រដ្ឋបាល និយ័តកម្ម ការប្រណាំងប្រជែង ច្បាប់ស្តីពីការអប់រំ ប្រព័ន្ធមុខងារសាធារណៈ សន្តិសុខសង្គម (២)**កត្តាសេដ្ឋកិច្ច** ៖កំណើនសេដ្ឋកិច្ច គោលនយោបាយថវិកា ចំណាយថវិកា ចំណាយអប់រំ គោលនយោបាយបៀវត្ស (៣)**កត្តាសង្គម** ៖ កម្រិតនៃការអប់រំ រចនាសម្ព័ន្ធសង្គមនៃប្រជាជន ជំនឿសាសនា អត្រាកំណើនប្រជាពលរដ្ឋ របាយប្រជាជនតាមអាយុ ភេទ ទំហំគ្រួសារ ជនជាតិភាគតិច (៤)**កត្តាបច្ចេកវិទ្យា**៖ ហេដ្ឋារចនាសម្ព័ន្ធ អគារសិក្សា អត្រាប្រើអ៊ីនធឺណែត ការប្រើប្រាស់បច្ចេកវិទ្យា ចំណាយលើការស្រាវជ្រាវ ។ល។
- គុណភាពនៃការគាំពារ និងការអប់រំកុមារតូចគឺជាគុណភាពនៃប្រព័ន្ធទាំងមូលតែម្តងដូចជាក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ និងសមាសភាពផ្សេងៗបូកសរុបចូលគ្នា ហើយបង្កើតជាការផ្តល់សេវាគាំពារ និងអប់រំកុមារតូចដែលប្រទាក់ក្រឡា។ សេវាប្រទាក់ក្រឡា *(Integrated services)* នាំឱ្យកុមារតូចទទួលបានផលប្រយោជន៍ និងគាំទ្រដល់ការពង្រឹងគុណភាពនៃការផ្តល់សេវាធានាបរិស្ថានសិក្សាមានស្ថិរភាព និងជួយដល់កុមារឆ្លងពីមត្តេយ្យសិក្សាទៅបឋមសិក្សា (Erickson et al., 2015)។

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្ដីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.២. ការរៀបចំយុទ្ធសាស្ត្រគំរូណែនាំនៃការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

#### ៤.២.២.១. យុទ្ធសាស្ត្រទី១ និងយុទ្ធសាស្ត្ររង ៣

#### ស្វ័យភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវ *ការពង្រឹងស្វ័យភាព* ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជាមានតម្លៃ PNI modified ខ្ពស់ជាងគេ ( PNI modified = 0.46) ដែលត្រូវបានចាត់ទុកថា ជាភាពខ្សោយជាងគេនៃគំរូណែនាំទម្រង់។

- យុទ្ធសាស្ត្ររងដ៏សំខាន់បង្កើតនៃការផ្តល់ស្វ័យភាព គឺ*ការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន។* គណៈកម្មការគ្រប់គ្រងសាលារៀនត្រូវបានបង្កើតឡើង ដោយមានការប្រជុំជាមួយមាតាបិតា អាណាព្យាបាល និងសហគមន៍។ ភារកិច្ចដ៏សំខាន់នៃគណៈកម្មការគ្រប់គ្រងសាលារៀនគឺការសិក្សាពីតម្រូវការសាលារៀន និងការដាក់ចេញនូវវិធានការ ដើម្បីបំពេញតាមតម្រូវការរបស់សាលារៀន (Bruns et al., 2011; Elmore, 2014; MoEYS, 2017; Gelsthorpe et al., 2003; Patrinos, et al., 2013; Fullan,2007; Hawley, 2007; ហង់ជួន, ២០២០)។

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្តីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.២. ការរៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

#### ៤.២.២.១. យុទ្ធសាស្ត្រទី១ និងយុទ្ធសាស្ត្រទី ៣

ស្វ័យភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

- *ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន* គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន ក្នុងការលើកកម្ពស់គុណភាពអប់រំកុមារតូច។ សារប្រយោជន៍នៃការចូលរួមរបស់សហគមន៍គឺបង្កើនការទុកចិត្តគ្នារវាងសហគមន៍ គ្រូបង្រៀន និងសាលារៀន។ ការទុកចិត្តនេះអាចកសាង និងកែលម្អការចូលរួម និងការបរិច្ចាករបស់សហគមន៍ជួយដល់សាលារៀន។ សមាសភាពនៃគណៈកម្មការគ្រប់គ្រងសាលារៀនមាន៖ (១) ប្រធាន ទទួលបន្ទុកមើលការខុសត្រូវប្រតិបត្តិការរួម (២) អនុប្រធាន ទទួលបន្ទុកការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលរៀន (៣) អនុប្រធាន ទទួលបន្ទុកការគ្រប់គ្រងមន្ត្រី (៤) សមាជិក ទទួលបន្ទុកការចូលរួមរបស់សហគមន៍ និងអភិបាលកិច្ចសាលារៀន (៥) សមាជិក ទទួលបន្ទុកការវាយតម្លៃសាលារៀន និងសិស្ស និង (៦) សមាជិក ទទួលបន្ទុកគណនេយ្យភាពសាលារៀន។

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្ដីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.២. ការរៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់ គុណភាពអប់រំកុមារតូចនៅកម្ពុជា

#### ៤.២.២.១. យុទ្ធសាស្ត្រទី១ និងយុទ្ធសាស្ត្រទ ៣ ស្វ័យភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

- *កំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ អាចសម្រេចបានតាម គោលដៅទាល់តែ នាយកសាលាត្រូវមាន ការប្ដេជ្ញាចិត្តខ្ពស់ និងគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវខ្ពស់ តាមរយៈការពង្រឹងភាពជាអ្នកដឹកនាំរបស់នាយកសាលា* (Bruns et al., 2011; Fullan, 2014; Hawley, 2007; MoEYS, 2017; Patrinos, et al., 2013; ហង់ជួន, ២០២០)។ កំណែទម្រង់ការគ្រប់គ្រងសាលារៀនប្រកបដោយការទទួលខុសត្រូវកម្រិតខ្ពស់ និងភាពជាម្ចាស់របស់គ្រឹះស្ថានសិក្សា ការធានាភាពស័ក្តិសិទ្ធិរបស់អ្នកដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន ដើម្បីបង្កើនការកៀរគរធនធាន និងការចូលរួមពីស្ថាប័ន និងវិស័យពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍន៍ ជាពិសេសសហគមន៍ អាណាព្យាបាល និងគ្រូបង្រៀន។

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្តីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.២. ការរៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

#### ៤.២.២.២. យុទ្ធសាស្ត្រទី២ និងយុទ្ធសាស្ត្រទី ៣

**គណនេយ្យភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា**

ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវ *ការពង្រឹងគណនេយ្យភាព* ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជាមានតម្លៃ PNI modified ខ្ពស់ជាងគេលំដាប់ទី២ (PNI modified= 0.45) ដែលត្រូវបានចាត់ទុកថា ជាភាពខ្សោយជាងគេនៃកំណែទម្រង់។

- *ការធ្វើផែនការកែលម្អសាលារៀន* គឺដើម្បីជួយសិស្ស គ្រូបង្រៀន មាតាបិតា សហគមន៍ អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធក្នុងមូលដ្ឋាន បានរួមគ្នាដោះស្រាយបញ្ហាប្រឈមចាំបាច់ មួយចំនួនផ្អែកលើលទ្ធផលសិក្សាសិស្ស។ ដូច្នេះសកម្មភាពនីមួយៗក្នុងផែនការកែលម្អសាលារៀន បានកំណត់មុខសញ្ញាអ្នកទទួលខុសត្រូវ ឬម្ចាស់សកម្មភាពជាក់លាក់ ដែលអាចប្រើសម្រាប់តាក់តែងសកម្មភាព និងលទ្ធផលនៃកិច្ចព្រមព្រៀងរបស់គ្រូបង្រៀន និងនាយកសាលា។

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្តីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.២. ការរៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

#### ៤.២.២.២. យុទ្ធសាស្ត្រទី២ និងយុទ្ធសាស្ត្រទ ៣

**គណនេយ្យភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា**

- ការលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជាទាមទារឱ្យបង្កើន*គណនេយ្យភាពរបស់នាយកសាលា*។ នាយកសាលា និងគ្រូបង្រៀនត្រូវមានស្វ័យភាព និងគណនេយ្យភាព ចំពោះសហគមន៍ មាតាបិតា និងអាណាព្យាបាលសិស្ស អំពីលទ្ធផលការសិក្សារៀនសូត្រ។ នាយក និងគ្រូមានតួនាទីក្នុងការជួយសិស្ស រៀនចេះ រៀនចប់ និងទទួលបាននូវលទ្ធផលល្អប្រសើរ។ ការប្រើប្រាស់ទិន្នន័យមានសុចរិតភាព ដូចជា លទ្ធផលសិក្សារបស់សិស្សដើមឆ្នាំ ប្រចាំខែ ត្រីមាស និងចុងឆ្នាំ។ ចំណូល និងចំណាយប្រចាំឆ្នាំ និងពិន្ទុស្តង់ដាសាលារៀនបានបំពេញនៅចុងឆ្នាំគឺត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដើម្បីបង្ហាញដល់សាធារណជននូវការទទួលខុសត្រូវរបស់សាលារៀនចំពោះមាតាបិតា សហគមន៍។ ការអនុវត្តបែបនេះបាននាំឱ្យសាធារណជន សហគមន៍ អាជ្ញាធរ និងគ្រប់អ្នកពាក់ព័ន្ធកសាងបាននូវការទុកចិត្តដល់សាលារៀន គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្តីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.២. ការរៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

#### ៤.២.២.២. យុទ្ធសាស្ត្រទី២ និង យុទ្ធសាស្ត្រទ ៣

**គណនេយ្យភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា**

- *គុណភាពបរិស្ថានសិក្សា* គឺជាកត្តាសំខាន់បំផុតក្នុងការលើកកម្ពស់សុខុមាលភាព និងការអភិវឌ្ឍរបស់កុមារ (Evans, 2006) បរិស្ថានសិក្សាទាំងក្នុងថ្នាក់ និងក្រៅថ្នាក់រៀនត្រូវអំណោយផលដល់កុមារតូចក្នុងការអភិវឌ្ឍ និងអាចរៀនសូត្របានគ្រប់ពេលវេលា ជាពិសេសនៅក្នុងពេលដែលពួកគេទៅសាលារៀន។ ធនធាននៅក្នុងសាលាមានគ្រប់គ្រាន់សម្រាប់ជួយលើកកម្ពស់ទំនាក់ទំនងគ្រូ និងសិស្ស និងដល់ការលេង ព្រមទាំងរៀនសូត្រ (Bruns et al., 2011; Elmore, 2014; Evans, 2006; Hawley, 2007; MoEYS, 2017; Patrinos, et al., 2013; ហង់ជួន,២០២០)។ បរិស្ថានសិក្សាគឺជាសូចនាករដំណើរការនៃគុណភាពអប់រំកុមារតូច ជាពិសេសបរិស្ថានហេដ្ឋារចនាសម្ព័ន្ធ សម្ភារសិក្សា និងការរៀបចំបន្ទប់រៀន (NICHD, 2000)។ *ប្រការនេះបានជាទំនាក់ទំនងគណនេយ្យភាពរវាងគណៈគ្រប់គ្រងសាលារៀនជាមួយមាតាបិតា និងរវាងសាលារៀនជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងជួយដល់ការលើកកម្ពស់ការអភិវឌ្ឍរបស់កុមារតូច។*

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្ដីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.២. ការរៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

#### ៤.២.២.៣. យុទ្ធសាស្ត្រទី៣ និងយុទ្ធសាស្ត្ររង ៣

**បង្កើនការយកចិត្តទុកដាក់ដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា**

ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវ *បង្កើនការយកចិត្តទុកដាក់ដល់គ្រូបង្រៀន* ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជាមានតម្លៃ PNI modified ខ្ពស់ជាងគេលំដាប់ទី៣ (PNI modified = 0. 44) ដែលត្រូវបានចាត់ទុកថា ជាភាពខ្សោយជាងគេនៃកំណែទម្រង់។

- *ការជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិល្អចូលធ្វើគ្រូបង្រៀន* យន្តការមានប្រសិទ្ធភាពក្នុងការជ្រើសរើសគ្រូ គឺដើម្បីជ្រើសរើសបុគ្គលដែលមានគុណសម្បត្តិសមស្របឱ្យក្លាយជាគ្រូបង្រៀន។ គណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ត្រូវទទួលខុសត្រូវក្នុងការជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍របស់ខ្លួន។ ថ្នាក់រៀនមួយត្រូវមានគ្រូបង្រៀនយ៉ាងតិចមួយនាក់។ ការជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍ត្រូវធ្វើឡើងដោយយុត្តិធម៌ តម្លាភាព និងគុណភាព។ មេឃុំចៅសង្កាត់អាចស្នើសុំការគាំទ្របច្ចេកទេសពីការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ក្នុងដំណើរការជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍។

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្តីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.២. ការរៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

#### ៤.២.២.៣. យុទ្ធសាស្ត្រទី៣ និងយុទ្ធសាស្ត្ររង ៣

**បង្កើនការយកចិត្តទុកដាក់ដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា**

- *ការបង្កើនប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភគ្រូ* ក្នុងលក្ខខណ្ឌសមស្របដើម្បីអាចរក្សាទុកក្នុងប្រព័ន្ធ។ បេក្ខជនដែលបានជាប់ជាស្ថាពរត្រូវចុះកិច្ចសន្យាជាមួយមេឃុំ ចៅសង្កាត់។ រាល់កិច្ចសន្យាត្រូវធ្វើឡើងមួយឆ្នាំម្តងហើយអាចបន្តកិច្ចសន្យាជាគ្រូមត្តេយ្យសិក្សាសហគមន៍សម្រាប់ឆ្នាំសិក្សាបន្តបន្ទាប់ក្រោយពីបានវាយតម្លៃជាប់ដោយគណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍។ ចំនួនប្រាក់ឧបត្ថម្ភផ្តល់ជូនគ្រូមត្តេយ្យសិក្សាសហគមន៍ត្រូវផ្អែកតាមការពិភាក្សាឯកភាពគ្នារវាងបេក្ខជនដែលបានជ្រើសរើស និងមេឃុំ ចៅសង្កាត់។

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្តីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.២. ការរៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

#### ៤.២.២.៣. យុទ្ធសាស្ត្រទី៣ និងយុទ្ធសាស្ត្រខ ៣

**បង្កើនការយកចិត្តទុកដាក់ដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា**

- *ការអភិវឌ្ឍគ្រូឱ្យទៅជាគ្រូដែលមានប្រសិទ្ធភាព* ដំណើរការមានប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈក្នុងគោលដៅធានាថាគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈ ដើម្បីក្លាយជាគ្រូដែលមានវិជ្ជាជីវៈខ្ពស់ដែលអាចសម្រេចបានលទ្ធផលសិក្សាសិស្សល្អប្រសើរ (McKinsey & Company 2007; Hanushek and Rivkin 2003) ។ គុណវុឌ្ឍិគ្រូជួយដល់ការកែលម្អគុណភាពនៃការគាំពារ និងអប់រំកុមារតូច ដោយសារគ្រូដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវនាំមកនូវគុណភាពនៃដំណើរការរៀន និងបង្រៀន (Bigras et al., 2010) ។

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្ដីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.២. ការរៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

#### ៤.២.២.៤. យុទ្ធសាស្ត្រទី៤ និងយុទ្ធសាស្ត្ររង ៣

**ជំរុញវាយតម្លៃការសិក្សា ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា**

ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវ *វាយតម្លៃការសិក្សា* ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជាមានតម្លៃ PNI modified ទាបជាងគេ ( PNI modified = 0. 44) ដែលត្រូវបានចាត់ទុកថា ជាភាពខ្លាំងនៃកំណែទម្រង់។

- *ការកែលម្អកម្មវិធីអប់រំកុមារតូច និងសៀវភៅគ្រូ ៖* កម្មវិធីសិក្សាមានតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងគុណភាពនៃការអប់រំ និងគាំពារកុមារតូច ដែលជួយដល់ការអភិវឌ្ឍពុទ្ធិបញ្ញា និងត្រៀមកុមារសម្រាប់ការចូលរៀនក្នុងសាលា ( Yoshikawa et al., 2013; Elmore, 2014; Hawley, 2007; Taguma et al., 2012; ហង់ជួន, ២០២០ ) ។ កម្មវិធីសិក្សាត្រូវមានគោលដៅសម្រេចបានការអភិវឌ្ឍគ្រប់ជ្រុងជ្រោយរបស់កុមារ ដូចជាការអភិវឌ្ឍរាងកាយ ការអភិវឌ្ឍពុទ្ធិបញ្ញា ការអភិវឌ្ឍសង្គម ការអភិវឌ្ឍផ្លូវអារម្មណ៍ (Emotional)ជាដើម។

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្ដីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.២. ការរៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

### ៤.២.២.៤. យុទ្ធសាស្ត្រទី៤ និងយុទ្ធសាស្ត្រទី ៣

**ជំរុញការវាយតម្លៃការសិក្សា ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា**

- *ការកែលម្អវិធីសាស្ត្ររៀន និងបង្រៀន៖* កម្មវិធីសិក្សាដែលទទួលបានជោគជ័យត្រូវផ្សារភ្ជាប់ទៅនឹងការបណ្ដុះបណ្ដាលគ្រូ និងការអនុវត្តគរុកោសល្យ ជាពិសេសត្រូវមានគ្រូដែលមានបទពិសោធជួយផ្ដល់ប្រឹក្សា និងគាំទ្រនៅក្នុងបន្ទប់រៀន (Bruns et al., 2011; Elmore, 2014; Gelsthorpe et al., 2003; Fullan, 2007; Hawley, 2007; MoEYS, 2017; ហង់ជួន, ២០២០) កម្មវិធីសិក្សាត្រូវផ្ដោតទៅលើការវាយតម្លៃតាមដំណាក់កាលផងដែរ ដើម្បីជួយគ្រូត្រួតពិនិត្យវឌ្ឍនភាពរបស់កុមារ និងជួយបង្រៀនកុមារម្នាក់ៗទៅតាមតម្រូវការផ្ទាល់ខ្លួន។ ក្របខ័ណ្ឌកម្មវិធីសិក្សា និងវិធីសាស្ត្រគរុកោសល្យ ត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ ដូចជាការបង្កើតតម្លៃកិច្ចសហការ ជំនឿទុកចិត្ត ស្វ័យភាព ការរៀនតាមបែបសកម្ម និងសុខុមាលភាពរបស់កុមារ។ ដើម្បីអនុវត្តកម្មវិធីសិក្សា និងគរុកោសល្យ ត្រូវមានកម្មវិធីបណ្ដុះបណ្ដាលគ្រូ ដោយកំណត់ចំនួនម៉ោងសិក្សាតាមមេរៀននីមួយៗ ការចូលរួមរបស់គ្រួសារការលេងល្បែងសិក្សា អន្តរកម្មរវាងគ្រូ និងសិស្ស ការគាំទ្រខាងផ្នែកសុខភាព និងអាហារូបត្ថម្ភ។

# ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

## ៤.២.ការពិភាក្សាស្ដីពីរបកគំហើញនៃការស្រាវជ្រាវ

### ៤.២.២. ការរៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា

#### ៤.២.២.៤. យុទ្ធសាស្ត្រទី៤ និងយុទ្ធសាស្ត្រទ ៣

**ជំរុញការវាយតម្លៃសិក្សា ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា**

- *ការផ្សព្វផ្សាយលទ្ធផលសិក្សារបស់សិស្សដល់ភាគីពាក់ព័ន្ធ* ៖ ការរៀបចំផែនការកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ត្រូវចាប់ផ្ដើមពីការពិនិត្យមើលលទ្ធផល នៃការវាយតម្លៃតាមកម្រិតថ្នាក់ តាមមុខវិជ្ជា និងតាមក្រុមកុមារតូច ដោយគ្រូប្រចាំថ្នាក់( Formative assessment )ហើយតាមរយៈទិន្នន័យទាំងនេះ គេអាចកំណត់ពីកម្រិតអភិវឌ្ឍរបស់កុមារ។ នាយកត្រូវយកលទ្ធផលសិក្សារបស់កុមារទៅពិភាក្សាជាមួយគ្រូបង្រៀន ដើម្បីកែលម្អវិធីសាស្ត្រគរុកោសល្យ កែលម្អកិច្ចតែងការបង្រៀន។ នាយកត្រូវជួបពិភាក្សាជាមួយមាតាបិតា ដើម្បីស្វែងយល់ពីការរំពឹងទុក ពីលទ្ធផលសិក្សារបស់សិស្សផងដែរ ជាពិសេសដើម្បីផ្ដល់ព័ត៌មានទាក់ទងនឹងការគាំពារ និងកម្មវិធីអប់រំមាតាបិតា និងបង្កើតបរិស្ថានវិជ្ជមាននៅផ្ទះ ដែលគាំទ្រដល់ការអភិវឌ្ឍរបស់កុមារ ជាពិសេសការបង្រៀនកុមារលេងល្បែងសិក្សា ការនិទានរឿង ការច្រៀងចម្រៀង អំណានជាដើម ( Elmore, 2004; Fullan, 2014; Hawley, 2007; MoEYS, 2017; Patrinos, et al., 2013; ហង់ជួន, ២០២០; UNICEF, 2020 )។

# ជំពូកទី៥

## ១. សេចក្តីសន្និដ្ឋាន



# ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.១. សេចក្តីសន្និដ្ឋាន

ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រ ជាពិសេស «យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១» ដែលរាជរដ្ឋាភិបាលនីតិកាលទី៧ បានដាក់ចេញ ការអនុវត្តកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សា គឺជាធាតុសំខាន់ក្នុងការលើកកម្ពស់ការផ្តល់សេវាអប់រំកុមារតូច ធានាបានសេវាអប់រំកុមារមានគុណភាព សមធម៌ និងបរិយាបន្ន។

ការអនុវត្តកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ធានាឱ្យបាននូវការអប់រំប្រកបដោយសមធម៌។ ក្នុងន័យនេះចាំបាច់ត្រូវមានផែនការអភិវឌ្ឍសាលាមត្តេយ្យសិក្សាសហគមន៍ ឱ្យក្លាយទៅជាសាលាមត្តេយ្យសិក្សាសហគមន៍មានស្តង់ដា និងមានស្តង់ដាពេញលេញ ➞ ការប្រែក្លាយសាលាមត្តេយ្យសិក្សាសហគមន៍មានស្តង់ដាពេញលេញ ➞ ឱ្យទៅជាសាលាបណ្តុញនៅក្នុងសាលាកម្រងដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស ➞ ធ្វើឱ្យមានការផ្លាស់ប្តូរនូវវប្បធម៌និងបរិយាកាសនៅក្នុងសាលារៀន គោលដៅនៃការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍។

ក្រសួងអប់រំ យុវជន និងកីឡាត្រូវពង្រឹងការធ្វើកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដោយប្រើប្រាស់វិធីសាស្ត្រការគ្រប់គ្រងសាលារៀនតាម " ប្រព័ន្ធបីអា 3A(s) បិទជិត" មានសមាសភាគដូចតទៅ (Bruns, Filmer and Patrinos 2011; World Bank 2003; World Bank 2010; Patrinos, 2010a)៖ ១. ស្វ័យភាព «Autonomy»៖ ការសម្រេចចិត្តនៅមូលដ្ឋានផ្តែកលើភស្តុតាង ២.គណនេយ្យភាព«Accountability»៖ ទទួលខុសត្រូវចំពោះការអនុវត្តរបស់សាលារៀន និងសិស្ស និង ៣.ការវាយតម្លៃ«Assessment»៖ ការអនុវត្តការងាររបស់សាលារៀន និងលទ្ធផលសិក្សារបស់សិស្ស។

# ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.១. សេចក្តីសន្និដ្ឋាន

ទន្ទឹមនឹងនេះ គេត្រូវយកចិត្តទុកដាក់ លើការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។ គ្រូដែលមានការអប់រំតាមវិជ្ជាជីវៈនៃការអប់រំកុមារតូច គឺជាកត្តាចម្បងនៃការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងជួយដល់ការអភិវឌ្ឍពុទ្ធិបញ្ញា និងបំណិនសង្គមរបស់កុមារតូច។

គ្រូបង្រៀនមិនត្រឹមតែមានគុណវុឌ្ឍិខ្ពស់ប៉ុណ្ណោះទេ តែត្រូវមានសមត្ថភាពនៅក្នុងការបង្កើតបរិស្ថានគរុកោសល្យ ដែលមានគុណភាពខ្ពស់។ **គរុកោសល្យមានគុណភាពគឺ៖** ១.យល់ពីការអភិវឌ្ឍកុមារតូច ២.អន្តរកម្មវិជ្ជមានរវាងគ្រូ និងសិស្ស ៣.ភាពជាអ្នកដឹកនាំដោះស្រាយបញ្ហា និងការរៀបចំកិច្ចតែងការ ៤. សមត្ថភាពបង្កើតបរិស្ថានការងារប្រកបដោយប្រសិទ្ធភាព។



# ជំពូកទី៥

## ២. អនុសាសន៍ដើម្បីប្រើប្រាស់ក្នុងការ ស្រាវជ្រាវ

# ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.២. អនុសាសន៍ដើម្បីប្រើប្រាស់ក្នុងការស្រាវជ្រាវ

*អនុសាសន៍ទី១៖* ក្រសួងអប់រំ យុវជន និងកីឡា ត្រូវពង្រឹងការធ្វើកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដោយប្រើប្រាស់វិធីសាស្ត្រ **«ការគ្រប់គ្រងតាមសាលារៀនតាមប្រព័ន្ធ បីអា 3A(s) បិទជិត»** ។ ការគ្រប់គ្រងបែបនេះជាការធ្វើវិមជ្ឈការ ការអប់រំតាមរយៈការគ្រប់គ្រងសាលារៀន ដើម្បីឱ្យសេវាអប់រំមានប្រសិទ្ធភាពដែលបង្ហាញតាមរយៈភស្តុតាងសមិទ្ធកម្ម នៃការអនុវត្តគោលនយោបាយអប់រំ ជំនួសឱ្យការគ្រប់គ្រងតាមបែបមជ្ឈការពីថ្នាក់កណ្តាល។

គោលដៅសំខាន់ គឺដើម្បី៖ ១. ផ្តល់ធនធាន និងអំណាច និងកសាងសមត្ថភាព ២.លើកម្ពស់គុណភាពនៃសេវាសាធារណៈមានប្រសិទ្ធភាព និងដោះស្រាយបញ្ហាទាន់ពេល ព្រមទាំង ៣. ជានានូវស្វ័យភាពមូលដ្ឋាន និងនយោបាយ តាមរយៈការចូលរួមរបស់សាធារណជនក្នុងការទទួលខុសត្រូវ និងដោះស្រាយបញ្ហា។

*ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍តាមប្រព័ន្ធ បីអា 3A(s) បិទជិត ឱ្យមានប្រសិទ្ធភាព គេចាំបាច់ត្រូវមានតួអង្គនាយកសាលា ដែលជាអ្នកមានតួនាទីស្នូលក្នុងការដឹកនាំអនុវត្ត។*

# ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.២. អនុសាសន៍ដើម្បីប្រើប្រាស់ក្នុងការស្រាវជ្រាវ

*អនុសាសន៍ទី២៖* ក្រសួងអប់រំ យុវជន និងកីឡា ត្រូវផ្តល់អាទិភាព ក្នុងការពង្រឹងគណនេយ្យភាពនៃសាលាមត្តេយ្យសិក្សាសហគមន៍ ដោយតម្រូវឱ្យសាលាមត្តេយ្យសិក្សាសហគមន៍បង្កើតផែនការកែលម្អសាលារៀន បង្កើនគណនេយ្យភាពរបស់នាយក និងលើកកម្ពស់ភាពជាដៃគូជាមួយសហគមន៍ក្នុងការកែលម្អបរិស្ថានសិក្សា ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។

គណនេយ្យភាពនៃការគ្រប់គ្រងសាលារៀន គឺនាយកត្រូវបង្ហាញឱ្យសាធារណជនឃើញថា រាល់បញ្ហាដែលបានលើកឡើងក្នុងផែនការកែលម្អសាលារៀន ជាពិសេសការសន្យាស្តីពីការសិក្សារបស់សិស្ស ត្រូវតែអនុវត្តឱ្យបានសម្រេច ហើយការចូលរួមធនធានពីសហគមន៍ដោយស្ម័គ្រចិត្តបានត្រូវយកទៅប្រើប្រាស់ ដើម្បីពង្រឹងការកែលម្អបរិស្ថានសិក្សា និងការគាំទ្រដល់ដំណើរការរៀន និងបង្រៀន ដើម្បីសម្រេចគោលបំណងដែលបានកំណត់នៅក្នុងផែនការកែលម្អសាលារៀន។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តភ្លាមៗ នូវយុទ្ធសាស្ត្ររង **«ការជំរុញបង្កើតផែនការកែលម្អសាលារៀន»** និង **« ការបង្កើនគណនេយ្យភាពរបស់នាយក »** ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។

*ការពិភាក្សាតាមក្រុមជាមួយអ្នកជំនាញអប់រំ និងមតិយោបល់របស់អ្នកពាក់ព័ន្ធឆ្លើយនឹងកម្រងសំណួរ បានស្នើសុំឱ្យពង្រឹងគណនេយ្យភាព ក្នុងការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍នេះផងដែរ។*

# ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.២. អនុសាសន៍ដើម្បីប្រើប្រាស់ក្នុងការស្រាវជ្រាវ

*អនុសាសន៍ទី៣៖* ក្រសួងអប់រំ យុវជន និងកីឡាត្រូវបន្តយកចិត្តទុកដាក់ដល់គ្រូបង្រៀន ដែលបម្រើការនៅសាលាមត្តេយ្យសិក្សាសហគមន៍ ដោយពង្រឹងការជ្រើសរើសបេក្ខជនមានលក្ខណសម្បត្តិល្អជាគ្រូបង្រៀន បង្កើនប្រាក់ឧបត្ថម្ភ និងការលើកទឹកចិត្តនានាដល់គ្រូមត្តេយ្យសិក្សាសហគមន៍ ព្រមទាំងពង្រឹងការបណ្តុះបណ្តាលគ្រូសាលាមត្តេយ្យសិក្សាសហគមន៍ឱ្យមានគុណភាព ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡាត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពយុទ្ធសាស្ត្រវង *«ពង្រឹងការជ្រើសរើសបេក្ខជនមានលក្ខណសម្បត្តិល្អជាគ្រូបង្រៀន» «បង្កើនប្រាក់បៀវត្ស និងការលើកទឹកចិត្ត »* និង *«ពង្រឹងការបណ្តុះបណ្តាលគ្រូប្រកបដោយគុណភាព »* ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។

*ការពិភាក្សាតាមក្រុមជាមួយអ្នកជំនាញអប់រំ និងមតិយោបល់របស់អ្នកពាក់ព័ន្ធឆ្លើយនឹងកម្រងសំណួរបានស្នើសុំឱ្យពង្រឹងការជ្រើសរើសបេក្ខជនមានលក្ខណសម្បត្តិល្អធ្វើជាគ្រូបង្រៀន និងកែលម្អការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ប្រកបដោយគុណភាពផងដែរ។ គ្រូបង្រៀន គឺជាកត្តាកំណត់ក្នុងការពង្រឹងគុណភាពអប់រំកុមារតូច ។*

# ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.២. អនុសាសន៍ដើម្បីប្រើប្រាស់ក្នុងការស្រាវជ្រាវ

***អនុសាសន៍ទី៤៖*** ក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តវិធីសាស្ត្រថ្មី ក្នុងការធ្វើការវាយតម្លៃការអប់រំកុមារតូច គឺ«*សេចក្តីណែនាំប្រតិបត្តិ ពីវិធីសាស្ត្រវាយតម្លៃសម្រាប់មត្តេយ្យសិក្សា*» ឆ្នាំ ២០២៤។

វិធីសាស្ត្រវាយតម្លៃថ្មីមិនទាមទារឱ្យធ្វើតេស្តទៅលើកុមារទេ តែត្រូវផ្តោតលើសមាសភាគសំខាន់ៗចំនួន ៥ ៖ *១.បញ្ចូលការធ្វើការវាយតម្លៃទៅក្នុងសកម្មភាពប្រចាំថ្ងៃ ២.ការសង្កេតកុមារនៅក្នុងសកម្មភាពជាក់ស្តែងធម្មតាដោយមិនដាក់សម្ពាធលើកុមារ ៣.ការបង្កើតសៀវភៅព័ត៌មានសម្រាប់សិស្សម្នាក់ៗ ដើម្បីកត់ត្រាគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍកុមារ ៤.ការផ្តល់ព័ត៌មានត្រឡប់ភ្លាមៗ ដើម្បីអនុវត្តវិធីសាស្ត្របង្រៀន ៥.ផ្តល់ឱកាសដល់កុមារបង្ហាញពីបំណិនក្នុងស្ថានភាពជាក់ស្តែង។* អាជ្ញាធរថ្នាក់ជាតិទទួលខុសត្រូវក្នុងការផ្តល់ធនធានថវិកា ដាក់ចេញគោលនយោបាយ និងធ្វើការវាយតម្លៃលទ្ធផលនៃសាលារៀន (Patrinos, Velez and Wang (2013)។

ក្រសួងអប់រំ យុវជន និងកីឡាត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពភ្លាមៗនូវយុទ្ធសាស្ត្ររង *«បង្កើនការផលិត និងប្រើប្រាស់កម្មវិធីអប់រំកុមារតូច និងសៀវភៅគ្រូ » «កែលម្អវិធីសាស្ត្ររៀន និងបង្រៀន »* និង *«បង្កើនការផ្តល់ព័ត៌មានពីលទ្ធផលសិក្សាសិស្សដល់មាតាបិតា »* ដោយដាក់បញ្ចូលវិធីសាស្ត្រវាយតម្លៃថ្មីទៅក្នុងយុទ្ធសាស្ត្ររងទាំងនោះ។

# ជំពូកទី៥ ៖ អនុសាសន៍

## ៥.២. អនុសាសន៍ដើម្បីប្រើប្រាស់ក្នុងការស្រាវជ្រាវ

*អនុសាសន៍ទី៥* ៖ តាមរយៈការពិភាក្សាតាមក្រុមជាមួយអ្នកជំនាញអប់រំ ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ខាងលើ ទាមទារឱ្យក្រសួងអប់រំ យុវជន និងកីឡារៀបចំផែនការសកម្មភាពលម្អិត៖ ១.ការកំណត់អាទិភាពយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្ររង និងនីតិវិធីអនុវត្ត ២.ការរៀបចំវិភាជន៍ថវិកា និងកំណត់ប្រភពថវិកាសម្រាប់ការអនុវត្ត និងគាំទ្រ ៣.ការកំណត់នូវសមត្ថភាពស្ថាប័ននៅគ្រប់កម្រិត ជាពិសេសនៅកម្រិតថ្នាក់ក្រោមជាតិ និងកម្រិតសាលាមត្តេយ្យសិក្សាសហគមន៍ ៤.ការរៀបចំផែនការអនុវត្តកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ ដើម្បីលើកកម្ពស់គុណភាពអប់រំកុមារតូច « *តាមវិធីសាស្ត្រផ្ទាវីក* »។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ សំដៅប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ឱ្យសម្រេចស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់ គ្រូបង្រៀន មាតាបិតា និងសហគមន៍។

*ក្រុមអ្នកជំនាញអប់រំបានលើកឡើងថា ការអនុវត្តកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍កម្រិតសាលារៀនត្រូវចាប់ផ្តើមពី៖ ១.ការកំណត់គោលដៅលទ្ធផលសិក្សារបស់សិស្ស ២.ការវាយតម្លៃពីគុណវុឌ្ឍិគ្រូមត្តេយ្យសិក្សាសហគមន៍នាពេលបច្ចុប្បន្ន។*

## ជំពូកទី៥

## ៣. អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ត



# ជំពូកទី៥ ៖ អនុសាសន៍

## ៥.៣. អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ត

*អនុសាសន៍ទី១៖* ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រ ជាពិសេស «យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១» ដែលរាជរដ្ឋាភិបាលនីតិកាលទី៧ បានដាក់ចេញ ការអនុវត្តកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ គឺជាធាតុសំខាន់ក្នុងការលើកកម្ពស់ការផ្តល់សេវាអប់រំកុមារតូច ធានាបាននូវការពង្រីកសេវាអប់រំកុមារមានគុណភាព សមធម៌ និងបរិយាបន្ន។

ការអនុវត្តកំណែទម្រង់ការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍ធានាឱ្យបាននូវការអប់រំប្រកបដោយសមធម៌។ ក្នុងន័យនេះចាំបាច់ត្រូវមានផែនការអភិវឌ្ឍសាលាមត្តេយ្យសិក្សាសហគមន៍ (១)ឱ្យក្លាយទៅជាសាលាមត្តេយ្យសិក្សាសហគមន៍មានស្តង់ដា និងមានស្តង់ដាពេញលេញ (២)ការប្រែក្លាយសាលាមត្តេយ្យសិក្សាសហគមន៍មានស្តង់ដាពេញលេញ ឱ្យទៅជាសាលាបណ្តាញនៅក្នុងសាលាកម្រង (៣)ដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស ធ្វើឱ្យមានការផ្លាស់ប្តូរនូវវប្បធម៌ និងបរិយាកាសនៅក្នុងសាលារៀនគោលដៅនៃការគ្រប់គ្រងសាលាមត្តេយ្យសិក្សាសហគមន៍។

*ក្នុងន័យនេះ នាពេលអនាគត គួរតែមានការសិក្សាបន្តទៀតពីលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រដែលបានដាក់ចេញខាងលើ ជាពិសេសវិភាគទាននៃសមាសភាគនីមួយៗ (១.ស្វ័យភាព ២.គណនេយ្យភាព ៣.ការយកចិត្តទុកដាក់ដល់គ្រូបង្រៀន និង ៤.ការវាយតម្លៃ) ទៅលើគុណភាពអប់រំកុមារតូច។*

# ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.៣. អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ត

*អនុសាសន៍ទី២៖* ការសិក្សាស្រាវជ្រាវនាពេលអនាគតត្រូវផ្តោតលើ ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។ គ្រូដែលមានការអប់រំតាមវិជ្ជាជីវៈនៃការអប់រំកុមារតូច គឺជាកត្តាចម្បងនៃការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងជួយដល់ការអភិវឌ្ឍពុទ្ធិបញ្ញា និងបំណិនសង្គមរបស់កុមារតូច។ គ្រូបង្រៀនមិនត្រឹមតែមានគុណវុឌ្ឍិខ្ពស់ប៉ុណ្ណោះទេ តែត្រូវមានសមត្ថភាពនៅក្នុងការបង្កើតបរិស្ថានគរុកោសល្យ ដែលមានគុណភាពខ្ពស់។ ការអភិវឌ្ឍវិជ្ជាជីវៈបន្តជួយគ្រូបង្រៀនឱ្យរៀនសូត្រពីឧត្តមានុភាព និងកែលម្អគរុកោសល្យ និងជួយជំរុញនូវការអភិវឌ្ឍកុមារ។ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន គឺជាសកម្មភាពផ្តោតលើការពង្រឹងចំណេះដឹង បំណិន និងសមត្ថភាពវិជ្ជាជីវៈរបស់គ្រូបង្រៀន ដែលនាំមកនូវការកែលម្អលទ្ធផលការសិក្សារបស់សិស្ស។

*ក្នុងន័យនេះ រូបមន្តនាពេលបច្ចុប្បន្នក្នុងការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍មិនទាន់ឆ្លើយតបទៅនឹងគុណភាពទេ។ ដើម្បីដោះស្រាយបញ្ហាចំពោះមុខ គេអាចប្រើប្រព័ន្ធបច្ចេកវិទ្យា ដូចជាកម្មវិធី **APP (Blended learning)** ជាប្រព័ន្ធម៉ូឌុល ជាវីដេអូ និងប្រព័ន្ធសិក្សាតាមបែបអេឡិកត្រូនិក សម្រាប់ការបណ្តុះបណ្តាលមុនចូលបំពេញការងារ និងការអភិវឌ្ឍវិជ្ជាជីវៈជាបន្ត ព្រមជាមួយការបង្កើតបណ្តាញសហគមន៍សិក្សាវិជ្ជាជីវៈជាដើម។*



# សូមអរគុណ!